KhmerPost.us

Printing The Cambodian world news!

ខ្មែរប៉ុស្ត៍

ឆ្មេរខាងកើត

EAST COAST BIWEEKLY PUBLICATION VOL. 04 ISSUE 65 AUG. 13-26, 2010

P.O. Box 24357. Philadelphia, PA 19120. Phone: 267.253.3947 Fax: 215.722.2226. KhmerPostUSA@gmail.com

សហរដ្ឋអាមេរិកបញ្ចប់សង្គ្រាមផ្ទាល់ដែនៅអ៊ីរ៉ាក់

អូបាម៉ា : "បន្ទាប់ពីខ្ញុំចូលកាន់កាប់សេដ្ឋវិមានបន្តិចមក ខ្ញុំបានប្រកាសយុទ្ធសាស្ត្រថ្មីសម្រាប់ប្រទេសអ៊ីរ៉ាក់ ដោយយើងត្រូវផ្លាស់ទៅវិញឱ្យមានការទទួលខុសត្រូវរបស់ពលរដ្ឋអ៊ីរ៉ាក់ខ្លួនឯង ។ ហើយខ្ញុំបានបញ្ជាក់យ៉ាងច្បាស់ថា យើងត្រូវធ្វើឱ្យបាននៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០នេះ គឺថាបេសកកម្មប្រយុទ្ធរបស់សហរដ្ឋអាមេរិក ត្រូវបានបញ្ចប់ហើយ ទាំងនេះគឺយើងច្បាស់ជាកំពុងតែធ្វើដូចសន្យា និងដូចកាលកំណត់" នេះគឺជាសេចក្តីថ្លែងការណ៍របស់លោកប្រធានាធិបតីនៃសហរដ្ឋអាមេរិក បារ៉ាក អូបាម៉ា កាលពីថ្ងៃចន្ទ ទី២ សីហា ឆ្នាំ២០១០ កន្លងទៅនេះ នៅក្រុងអាត្លង់តា ។

(នៅទំព័រទី ០៦)

មានអ្វីល្អែកនៅឆ្មើឡាដែលឆ្មៀ

I. ឋានៈញែល ពៅ ជានត្រូវចំឡើងឋានៈស្មើភ្លឺជាឋានៈយកសាលាអ្នក

•នេះជាតួនាទីដ៏សំខាន់បំផុតមួយសម្រាប់សហគមន៍ខ្មែរដែលគេពុំដែលបានទទួលនៅរដ្ឋផែនស៊ីវេនានេះពីមុនមកទេ ។ ដានីញ្ញែល និងចេញពីតួនាទីជានាយករងនៅ Furness H.S ទៅកាន់តួនាទីជានាយកសាលា G.W. Childs Elemen. School នៅបវេស្សនកាលខាងមុខនេះហើយ ។ ព័ត៌មាននៃការដង្ហែឡើងបុណ្យស័ក្តិនៅក្រសួងអប់រំរបៀបនេះ បានធ្វើឡើងស្របគ្នានឹងការទាមទាររបស់ក្រុមអ្នកដឹកនាំសហគមន៍ខ្មែរ បាននាំគ្នាទាមទារឱ្យមានការតែងតាំងឱ្យមានតួនាទីសំខាន់ៗសម្រាប់ជម្រុញឱ្យការសិក្សារបស់សហគមន៍ខ្មែរ អាចឈោងរកភាពរីកខ្ពស់ឡើងទៅបាន ។ តួនាទីថ្មីរបស់ ដានីញ្ញែល ពៅ ច្បាស់ជាមិនត្រឹមតែជាមោទនភាពសម្រាប់ខ្លួនឯង និងក្រុមគ្រួសារផ្ទាល់ប៉ុណ្ណោះទេ គឺជាភាពរីករាយ ញញឹមញញឹមរបស់សហគមន៍ខ្មែរ ចំពោះវិស័យអប់រំទៀតជាមិនខាន ។ **(តទៅទំព័រទី១១)**

មាតិការឿង

១- ឌុច សម្លាប់មនុស្សជាង១ម៉ឺននាក់	..... ០៣
២- ការសាទរខួបក្រុងខ្មែរឆ្នាំទី៣	..... ០៤
៣- ប្រវត្តិព្រះអាចារ្យ ហែម ថៀវ (ត)	..... ០៥
៤- ក្តីស្នេហ៍គ្មានទីបញ្ចប់ និងកិច្ចសម្ភាសន៍	..... ០៦
៥- Cambodia Daily	..... ០៨
៦- មួយរាត្រី...៣៥ឆ្នាំ និងទំព័រអាកាសខ្មែរ	..... ១៣
៧- អាថ៌កំបាំង និងសិល្បៈនៃជីវិត	..... ១៤
៨- នាទីប្រវត្តិសាស្ត្រ និងនាទីព្រះពុទ្ធសាសនា	..... ១៥

គណបក្សសិទ្ធិមនុស្ស

Human Rights Party

បំរើ ការពារ កសាង

ពិធីឧបលើកទឹកចិត្ត របស់គណបក្សសិទ្ធិមនុស្ស

យើងជាសមាជិក សមាជិកា គណកបក្សសិទ្ធិមនុស្ស ប្រចាំនៅសហរដ្ឋអាមេរិកខាងជើង និងកាណាដា សូមគោរពអញ្ជើញ អស់លោក លោកស្រី អ្នកនាងកញ្ញា មកចូលរួមកម្មវិធីជប់លៀងគំរប់ខួបលើកទីពីរ របស់គណបក្សសិទ្ធិមនុស្ស នៅល្ងាចថ្ងៃសៅរ៍ ទី២៨ ខែសីហា ឆ្នាំ ២០១០ នៅទីក្រុងហ្វីឡាដែលហ្វៀ ។

ទីកន្លែង : នៅភោជនីយដ្ឋាន Hai Tien

អាស័យដ្ឋាន : 1601 Washington Ave,16th Street, Philadelphia, PA 19146.
Phone : 215-732-8970

ពេលវេលា : ចាប់ពីម៉ោង៦ល្ងាច រហូតដល់ម៉ោង ១២ អធ្រាត

វាគ្មិនកិត្តិយស : ឯកឧត្តម កឹម សុខា អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម និងប្រធានគណបក្សសិទ្ធិមនុស្ស និងលោកជំទាវ

ព័ត៌មានបន្ថែមសូមទាក់ទង :

ប៊ុត វិសាខា	២៦៧-៤០១-៨៥៩២	ឡុង ញឹម	២៦៧-៦៧១-៨៧៨៤
ចាន់ វិស្សអ័រប	២១៥-២៥៩-៣២៤	ប៉ូ កើង	៨៦៧-២៨៦-២៦០៦
ព្រៃ ហ៊ាល	២១៥-២៥៤-៩៦៨២	ឃួ គីមសេង	២៦៧-២២៦-១៤៥២
ហ៊ូ គេង	២៦៧-៣៨៣-៧៧១០	វ៉ា សាម៉ុន	២១៥-៣៥៦-៦៧៨១
អ៊ឹម ឈឿម	៣០២-៣៧៧-៧៧១០	លោកស្រី ស្រេង លក្ខិណា	២៦៧-៣០៣-៩០២៥
ឡុង និច	២៦៧-២៨២-៨៤០២	ម៉ម ឃីន	២១៥-២០០-៣៨១០
ចាន់ សុវណ្ណ	២៦៧-២៥៨-៨០៩០	ចាន់ អាត	២៦៧-៥៧០-៩៥៦៨
ម៉ៅ ម៉ន	២១៥-៣៣៦-៣០៣៩	ជា ប៊ុនឡេង	២១៥-២៧១-៣៧៧៥
អ៊ិន តាំងហ្គ	២១៥-២៨០-៦៥៧៦	រស់ ប៊ាន	៩០៥-៣៥២-២៥៧៩

យើងខ្ញុំជាសមាជិក សមាជិកានៃគណបក្សសិទ្ធិមនុស្ស សូមគោរពអញ្ជើញ អស់លោក លោកស្រី ញាតិមិត្តជិតឆ្ងាយទាំងអស់ឱ្យបានចូលរួមក្នុងកម្មវិធីលើកខួបលើកទីពីរ របស់គណបក្សសិទ្ធិមនុស្សឱ្យបានច្រើនកុះករ ដើម្បីជួយឧបត្ថម្ភគាំទ្រនូវស្មារតីជាតិ ជាពិសេស គឺជំរុញប្រជាពលរដ្ឋទូទៅ ទាំងក្នុង និងក្រៅប្រទេសជាដែរ ។ ដើម្បីជាព័ត៌មានផ្សេងៗសូមបើកទៅបណ្តាញ www.hrpcambdia.info ។ សូមជួយជាវិភាគទានតាមចំណុះសេចក្តី ដើម្បីឧបត្ថម្ភនូវកម្មវិធីនយោបាយនេះជាដែរ

វិទ្យុសម្លេងសិទ្ធិមនុស្ស ជាវិទ្យុសម្លេងអ្នកតស៊ូដើម្បីសេរីភាព !

MENG'S CLEANERS

454 E. Wyoming Avenue. Philadelphia, Pa 19120. Tel. 215-329-2593

ផ្ទះយើងមានកាត់ដេរសំពត់អាវ ច្រើនម៉ូដ និងកែសម្រួលជូនបាន

WE NOW DO CUSTOM DESIGN TAILORING AND ALTERATIONS

-ផ្ទះយើងមានជំនាញខាងកាត់ដេរតាមម៉ូដ បូរាណ ឬសម័យ

-យើងមានជំនាញកាត់ដេរគំរូសំពត់អាវតូចធំ បានតាមការស្រម័យ

-យកក្រណាត់មកឱ្យយើងដេរ ឬក៏ទិញ

PLEASE CALL CHANY SOT 215-329-2593 សូមទូរស័ព្ទរក ឆនី សុទ្ធ នៅលេខ (215) 329 2593 ដើម្បីពិគ្រោះ

KOCH INVESTIGATIONS & SECURITY SERVICES

2400 South 6th Street. Philadelphia, PA 19148

TEL. 215-380-5127

↙យើងក្សាសុវត្ថិភាពនៅ គោដនីយដ្ឋាន ហាងលក់ទំនិញតូចធំ

↙ធ្វើការជូនពេលថ្ងៃធ្វើការ ពេលយប់នឹងចុងសប្តាហ៍

↙ការពារដោយអាវុធ ឬក៏គ្មានអាវុធ

↙តម្លៃទាបបំផុត

Investigative Services

- Undercover Investigations
- Embezzlement and fraud
- Surveillance, Video and Still Photos
- Criminal Investigations

Security Services

- Security Guards
- Executive Protection
- Personal Protection
- Doorman
- Security Audio/Video Equipment
- Computer Security

សេវាខាងស៊ើបអង្កេត

- ស៊ើបអង្កេតជាសម្ងាត់
- ស៊ើបរឿងបន្ទំលួចប្រាក់
- ឃាមតាមវីដេអូ និងតាមថតរូប
- ស៊ើបរឿងខាងឧក្រិដ្ឋកម្ម

សេវាខាងសុវត្ថិភាព

- បុគ្គលិកខាងសន្តិសុខ
- បុគ្គលិកការពារថ្នាក់ដឹកនាំ
- បុគ្គលិកការពារផ្ទាល់ខ្លួន
- អ្នកឃាមកាម
- សម្ភារៈការពារសុវត្ថិភាពដោយសម្លេង ឬរូបវីដេអូ
- មានលក់ និងដំឡើងសម្ភារៈកុំព្យូទ័រការពារសន្តិសុខ ដែលទទួលការអនុញ្ញាតពីក្រសួង ប៉ូលិស និងក្រសួងការពារក្រុងហ៊ីឡាដែលហ្សៀ

សេវាគុណភាពខ្ពស់ ចេះប្រើភាសាខ្មែរ ភាសាចិន វៀតណាម និងឡាវ

"កុងស៊ើបអង្កេតនិងសុវត្ថិភាព"

ភាពខុសគ្នា គឺយើងយកចិត្តទុកដាក់ពីលោកអ្នក

OPERATION TOWN WATCH DIAL 911

PHILADELPHIA POLICE

ឪុច សម្លាប់មនុស្សជាង១ម៉ឺននាក់ទោសជាប់គុក១៩ឆ្នាំ

* តើការកាត់ទោស ឪុច របស់តុលាការខ្មែរក្រហមវាសាកសមទៅនឹងទោសកំហុសដែលបានប្រព្រឹត្តដែរឬទេ ?

ខ្មែរប៉ុស្ដិ៍ : មាជ សុវណ្ណារ៉ា, គីម សុជាតិ

●●● ការប្រកាសសាលក្រមជាស្ថាពរដើម្បីផ្ដន្ទាទោសអតីតមេគុកឈ្មោះ កាំងហ្គិចអ៊ាវ ហៅ ឪុច កាលពីព្រឹកថ្ងៃទី26 កក្កដានេះ បានធ្វើឱ្យរំជើបរំជួលពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដោយមតិភាគច្រើនបានប្រតិកម្មចំពោះសាលក្រមថា ឪុច មិនគួរសាកសមទទួលកំហុសទោសរយៈពេល19ឆ្នាំទេទៅនិងទង្វើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលគាត់បញ្ជាឱ្យមានការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ និងសម្លាប់ដល់ជនស្លូតត្រង់ជាងមួយម៉ឺននាក់ ។ ដោយពួកគេចង់ឱ្យ ឪុច ជាប់គុកអស់មួយជីវិត ប៉ុន្តែអ្នកដែលមានគំនិតសមស្របទៅនិងសេចក្ដីសម្រេចរបស់តុលាការខ្មែរក្រហមកូនកាត់អង្គការសហប្រជាជាតិមួយនេះបាននិយាយថា វាមិនមែនជាការទាស់ខុសអ្វីទេ បើទោះបីច្បាប់កំណត់ផ្ដន្ទាទោសដល់រូប ឪុច 35ឆ្នាំ ហើយបូកដកកាត់បន្ថយ5ឆ្នាំ ដោយសារ ឪុច សហការជាមួយតុលាការក្នុងការឆ្លើយបំភ្លឺ និងផ្ដល់ភស្ដុតាង ដោយរួមទាំងគិតបញ្ចូលការដែល ឪុច ត្រូវបានចាប់ឃុំខ្លួនតាំងពីឆ្នាំ1999 ទៀតនោះ ឃើញថា ឪុច ត្រូវតែជាប់គុកត្រឹមតែជាង18ឆ្នាំប៉ុណ្ណោះ ។ ប៉ុន្តែត្រូវគិតថា ឪុច មានអាយុជិត70ឆ្នាំទៅហើយ ដូច្នេះ បន្ថែមអាយុជាប់គុក19ឆ្នាំទៀត ឃើញថានឹងជាប់គុកអស់មួយជីវិតទៅហើយ ។

ប្រធានគណបក្សសិទ្ធិមនុស្ស លោក គីម សុខា ក្រោយប៉ុន្មានម៉ោងនៃការប្រកាសសាលក្រមជាស្ថាពរផ្ដន្ទាទោស ឪុច នោះបានសម្ដែងការចាប់អារម្មណ៍យ៉ាងដូច្នេះថា :

គីម សុខា : ចំពោះខ្ញុំ ខ្ញុំគិតថា ប្រសិនណាជាយើងកាត់ទៅ35ឆ្នាំរាប់ពីឥឡូវទៅ ហើយអាយុគាត់ចិតសិបជាងនោះ អាចដល់ពេលត្រូវស្លាប់ហើយ ។ ដល់ឥឡូវឮគេទូទាត់ពីមុនអស់ទៅនៅសល់តែជាង10ឆ្នាំនោះទេ វារាងស្ទើបន្តិច រឿងនេះវាមិនសមទៅនឹងទង្វើទោសកំហុសរបស់គាត់នោះទេ ។ ក៏ប៉ុន្តែយុត្តិធម៌វាអាចរកបានមួយជំហានទៅហើយចំពោះការកាត់ទោសពួកឧក្រិដ្ឋជនពួកនៃមេដឹកនាំនយោបាយ ដែលយកប្រជាពលរដ្ឋឯងទៅសម្លាប់ហ្នឹង អ្នកដឹកនាំខ្មែរដែលធ្វើទារុណកម្មកាប់សម្លាប់ខ្មែរគ្នាឯងហ្នឹង យើងយកមកកាត់ទោសអីចឹងក៏ជាគំរូមួយឱ្យមេដឹកនាំក្រោយៗហ្នឹងកុំឱ្យប្រព្រឹត្តិអីចឹងទៀត ។

ឪុច ត្រូវបានគេដឹងថា បានដឹកនាំមន្ទីរសួចម្ហើយស.21 ហៅថា គុកទួលស្លែងបានបង្ហាញពីចំនួនខុសត្រូវចំពោះអាយុជីវិតមនុស្ស12,484 នាក់ដែលត្រូវបានធ្វើទារុណកម្ម និងសម្លាប់ ។ ឪុច បានទទួលខុសត្រូវបានដាក់ចេញនូវវិធីសាស្ត្រសួចម្ហើយជាច្រើនដើម្បីបង្ខំយកចម្ហើយសារភាពពីជនជាប់ចោទពីកម្មាភិបាលខ្មែរក្រហម ឬជនទាំងឡាយណាដែលត្រូវបានចាប់បញ្ជូនមកមន្ទីរ ស.21 ដូចជាការឆក់ខ្សែភ្លើងដកក្រចកដៃ ក្រចកជើង ចងព្យួរជើងឡើងលើដោយជ្រមុជក្បាលទៅក្នុងទឹក ការស្រោបថង់ប្លាស្ទិកដើម្បីធ្វើឱ្យថប់ដង្ហើមជាដើម ។ ទាហានមួយចំនួនត្រូវបានគេបោកខ្ចប់និងដើមឈើក្រោយឆ្នាំ 1979 មានតែជនរងគ្រោះចំនួនតែ7នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិត ក្នុងនោះ មានកុមារាចំនួន2 នាក់បានរួចផុតពីការស្លាប់ ។ មុនប៉ុន្មានម៉ោងក្នុងការឡើងយន្តហោះមកកាន់សហរដ្ឋអាមេរិកលោក គីម សុខា ដែលជាប្រធានគណបក្សសិទ្ធិមនុស្ស បានថ្លែងប្រាប់វិទ្យុខ្មែរប៉ុស្ដិ៍ឱ្យដឹងថា

គីម សុខា : ប៉ុន្តែសម្រាប់ខ្ញុំវិញ ខ្ញុំគិតថា យុត្តិធម៌ក្នុងរបបប្រល័យពូជសាសន៍នេះគ្រាន់តែកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងអស់នេះ មកដាក់ទោស50ឆ្នាំ 100ឆ្នាំវាមិនគ្រប់គ្រាន់ ហើយក៏គ្មានយុត្តិធម៌ពេញលេញដែរ ពីព្រោះយើងទាំងអស់គ្នាដឹងហើយថា ខ្មែរក្រហមដែលឡើងកាន់អំណាចបានអាចមកសម្លាប់ប្រជាពលរដ្ឋខ្មែរគ្នាឯងបាននោះ គឺដោយសារមានបរទេសនៅពីក្រោយខ្នង មានបរទេសគេជួយឧបត្ថម្ភគាំទ្រពួកខ្មែរក្រហម រហូតដល់ពួកខ្មែរក្រហមឡើងកាន់អំណាច ។ យើងដឹងហើយថា ខ្មែរក្រហមទាំងនោះកើតមកពីណា តាំងពីឈូនអ្នកបង្កើតមក រហូតដល់ក្រោយឡៃតចិនជួយគាំទ្រឡៃត ។ **អីចឹងប្រទេសទាំងអស់នោះដែលគាំទ្រជួយជ្រោមជ្រែងខ្មែរក្រហម** រហូតដល់ខ្មែរក្រហមមានអំណាចមកសម្លាប់ខ្មែរគ្នាឯងនោះ ប្រទេសទាំងអស់នោះរួចខ្លួនទទេកាត់ទោសត្រឹមតែពួកខ្មែរ ។ អីចឹងយុត្តិធម៌យើងបានត្រឹមតែគ្រោងទេ បើចង់ឱ្យខ្មែរបានយុត្តិធម៌ពេញលេញបំបាត់នូវការឈឺចាប់ពីការប្រល័យពូជសាសន៍ មែនទែនទាល់តែប្រទេសដែលនៅពីក្រោយខ្នងដែលជួយឱ្យខ្មែរក្រហមកាន់អំណាចនោះ ឱ្យប្រទេសនោះសងជំងឺចិត្តដល់ប្រទេសខ្មែរ ឬប្រជាពលរដ្ឋខ្មែរដែលរងគ្រោះដោយស្លាប់ និងប្រទេសខ្មែរដែលខ្ចេចខ្ចាំហ្នឹងផងបាទ ! ។

ចំណែកបេសកកម្មនៃគណៈកម្មាធិការប្រព្រឹត្តិកម្មខ្មែរដើម្បីយុត្តិធម៌ និងសមធម៌លោក សួន សេរីរដ្ឋា បានប្រតិកម្មយ៉ាងដូច្នេះដែរថា :

សួន សេរីរដ្ឋា : ចំពោះខ្ញុំយល់ថា ករណីប្រកាសសាលក្រមកាត់ក្ដី ឪុច ដែលជាមេគុកទួលស្លែងនេះ បើទោះបីជាមិនមានយុត្តិធម៌ពេញលេញយ៉ាងណាក៏ដោយ ក៏ប៉ុន្តែវាជាគំរូយុត្តិធម៌មួយ ។ ពីព្រោះបើតាមការដែលរៀបចំរបស់អង្គការសហប្រជាជាតិរឿងសាលាក្ដីខ្មែរក្រហមនេះ គឺថាគេចាត់ទុកសាលាក្ដីខ្មែរក្រហមធ្វើយ៉ាងណាឱ្យមានគំរូបីសំខាន់ទី1 គឺថាគំរូគោរពសិទ្ធិមនុស្ស ទី2 គឺគំរូឱ្យមានយុត្តិធម៌សង្គម ទី3 គឺថាគំរូលុបបំបាត់វប្បធម៌រួចទោស ។ អីចឹងករណីនេះមិនមានយុត្តិធម៌ពេញលេញ មិនមានសមធម៌ត្រឹមត្រូវ ក៏ប៉ុន្តែជាគំរូមួយហើយបងប្អូនគួរតែទទួលយកថា វាជាគំរូយុត្តិធម៌មួយនៅក្នុងសាលាក្ដីដែលអន្តរជាតិបានបង្ហាញឱ្យកម្ពុជាថា អ្នកដែលទទួលរងគ្រោះ គឺត្រូវតែមានយុត្តិធម៌ ហើយអ្នកដែលប្រព្រឹត្តិបទឧក្រិដ្ឋកម្ម គឺត្រូវតែទទួលទោស ។ ប៉ុន្តែការស្ងាប់របស់ពលរដ្ឋខ្មែរជាង2លាននាក់មិនមែនស្ថិតនៅក្រោមដៃរបស់ ឪុច ទេ ។ ឪុច គ្រាន់តែជាអ្នកទទួលបញ្ជាដូច្នេះអ្នកដែលទទួលបញ្ជាសម្លាប់ ហើយអ្នកដែលបង្កើតរបបខ្មែរក្រហមអ្នកដែលជ្រោមជ្រែងរបបខ្មែរក្រហម ហើយអ្នកដែលនៅពីក្រោយការបញ្ជាសម្លាប់នៅក្នុងរបបខ្មែរក្រហម ជាពិសេសបរទេសដែលជាប្រទេសចិន ជាប្រទេសយួនដែលគេនៅពីក្រោយនៃការសម្លាប់នេះ។ ហេតុដូច្នេះបើសិនជាយើងប្រៀបធៀបអ្នកដែលមានតួនាទីប្រហាក់ប្រហែល ឪុច ក្នុងប្រទេសកម្ពុជា គឺមានប្រហែលជា2រយនាក់ផ្ទាយ ។ ពីព្រោះជាទូទៅនៅក្នុងប្រទេសកម្ពុជា ក្នុងរបបខ្មែរក្រហមហ្នឹង គឺមានមន្ទីរសន្តិបាល ឬគុកមានជាង200កន្លែង ហើយមួយកន្លែង១សម្លាប់មនុស្សអស់តិចបំផុតក៏ 1ម៉ឺននាក់ដែរ ។ ហេតុដូច្នេះ គឺថាមេគុកទាំងអស់នោះមិនទាន់ស្លាប់អស់ទេ ហើយមួយចំនួនធំកំពុងមានតួនាទីនៅក្នុងរដ្ឋាភិបាលក្នុងពេលបច្ចុប្បន្នហ្នឹង ពិសេសជាសមាជិករបស់គណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច គឺគេមានតួនាទីតាំងពីចៅហ្វាយខេត្តថ្នាក់ មេបញ្ជាការកងទ័ព តំណាងរាស្ត្រ រដ្ឋមន្ត្រី ។ ឧទាហរណ៍ដូចជា លោក តាត ឈន់, លោក ហោ ណាំហុង ជាដើម អ្នកទាំងអស់នេះសុទ្ធតែមានតួនាទីមានកាតព្វកិច្ចនៅក្នុងរបបខ្មែរក្រហម ហើយសុទ្ធតែជាអ្នកទទួលខុសត្រូវចំពោះការស្ងាប់របស់ពលរដ្ឋខ្មែរនៅក្នុងការគ្រប់គ្រងអំណាចរបស់ខ្មែរក្រហម ក៏ប៉ុន្តែគេមិនបានយកអ្នកទាំងអស់នេះមកកាត់ទោសទេ ហើយចំពោះក្រុមមន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាជនកម្ពុជាមានលោក ហ៊ុន សែន, លោក ជា ស៊ីម, លោក ហេង សំរិន ក៏ជាមន្ត្រីកងទ័ពនៅក្នុងភូមិភាគបូព៌ាក្រោមការគ្រប់គ្រងរបស់លោក សោ ភឹម ហើយក៏មានជាប់ពាក់ព័ន្ធការសម្លាប់ពលរដ្ឋខ្មែរនៅក្រោយឆ្នាំ1976 ដើមឆ្នាំ1977 ជាងមួយលាននាក់ដែរ មុននឹងពួកនេះរត់ទៅស្រុកយួន មុននឹងពួកទាំងនេះទៅជាប់គុកនៅស្រុកយួន ពួកទាំងនេះបានជាប់ពាក់ព័ន្ធសម្លាប់បងប្អូននៅភូមិភាគបូព៌ា ដូចជានៅខេត្តក្រចេះ នៅស្រុកឆ្លូង ស្រុកមេមត់ ខេត្តកំពង់ចាម នៅព្រៃវែង នៅខាងខេត្តស្វាយរៀង គឺសុទ្ធតែមានពាក់ព័ន្ធនឹងអស់លោកគណបក្សប្រជាជនកម្ពុជា គឺលោក ហ៊ុន សែន, លោក ជា ស៊ីម និងលោក ហេង សំរិន ។ ដូច្នេះករណីនេះគឺថា ពុំទាន់បានហៅអ្នកទាំងអស់នេះមកកាត់ទោសទេ គឺនៅមានច្រើនទៀត ។ សម្ដេច នរោត្តម សីហនុ ក៏មានតួនាទីនៅក្នុងរឿងនេះដែរ ក៏ពុំទាន់បានប្រកាសយកមកសួរដើម្បីដេញដោលអំពីទោសកំហុសនៃការទទួលខុសត្រូវដែរ ។ ដូច្នេះ ករណី ឪុច គ្រាន់តែជាករណីតូចមួយ ។ លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនឯករាជ្យកម្ពុជាលោកបានមានប្រសាសន៍យ៉ាងដូច្នេះថា :

រ៉ុង ឈុន : តាមការពិតអ្នកប្រព្រឹត្តិបទឧក្រិដ្ឋកម្មមនុស្សជាតិត្រូវតែទទួលការកាត់ទោសទទួលការវិនិច្ឆ័យហើយ ។ បើយើងមើលពីវិសាលភាពនៃច្បាប់

(តទៅទំព័រទី ១៦)

រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា

តោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)

Nam Vang Restaurant

571 Unit # 1 Adams Avenue, Philadelphia, Pa 19120
(inside Hong Kong Market) (215) 742-9488
Open 7 days a week from 9 a.m. – 9 p.m.

បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 យប់

១_មុខជំនាញខាងម្ហូបខ្មែរយ៉ាង ចំណាន ឬចង់ថា:
- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ដាំង ឆារសាច់គោ
- មីកន្ដាំងឆារគ្រឿងសមុទ្រ
- បាយឆារគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង



២_មុខជំនាញម្ហូបវ្រៃតណាម ឈ្ងុយឆ្ងាញ់ ឬចជា:
- នំបញ្ចុកទឹកត្រីពិសេស
- នំប៉័ងបាតេ ឬសាច់គោអាំង
- ខគោ នំប៉័ង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង

អឿនរាល់ថ្ងៃលោកអ្នកអាចពិសាធីកក្រុងគ្រប់រស់ជាតិផ្លែឈើ ដូចជា : ឪុរេន ឬ អាវុកាដូ ហើយជាពិសេស មានធីកអំពៅកិនស្រស់ៗ

ការសាទរខួបក្រុងខ្មែរឆ្នាំទី៣មានការរិះគន់ថាមិនឯកភាពខ្មែរ

ខ្មែរប៉ុស្ដិ៍ : ភ៉ានាថ

•••ក្រុមអ្នកនយោបាយមិនថាខ្មែរ ឬសហរដ្ឋអាមេរិកបានសម្តែងសាទរ និងការឱ្យតម្លៃនៃមោទនភាពចំពោះបងប្អូនខ្មែរ-អាមេរិកាំង ដែលបានខិតខំប្រឹងប្រែងលើកមុខមាត់សហគមន៍របស់ខ្លួនឱ្យក្លាយទៅជាក្រុងខ្មែរ ដោយពួនផ្តុំជាតំបន់សេដ្ឋកិច្ចមួយបន្ទាប់ពីរដ្ឋាភិបាលតំបន់ក្រុង Long Beach បានអនុម័តសម្រេចឱ្យជាផ្លូវការកាលពីឆ្នាំ2007 ។

កាលពីរាត្រីថ្ងៃសុក្រ ទី9 ខែកក្កដា ឆ្នាំ 2010 នៅចំកណ្តាល បេះដូងនៃទីក្រុងខ្មែរ Long Beach តាមបណ្តោយផ្លូវ Anaheim ផ្តុំទៅដោយទីប្រជុំជនខ្មែរមានហាងចំនិញជួញដូរនោះគេឃើញបងប្អូនខ្មែរនិងជាតិសាសន៍ដទៃដែលសុទ្ធតែជាឈ្មួញមន្ត្រីរដ្ឋការអាមេរិកប្រមាណ300នាក់បានជួបជុំគ្នានៅក្នុងពិធីប្រារព្ធខួបឆ្នាំទី3នៃការកើតឱ្យមានក្រុងខ្មែរនោះ គេសង្កេតឃើញសារលិខិតពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានបញ្ជាក់កោតសរសើរចំពោះបងប្អូនជនរួមជាតិទាំងអស់ដែលបានរក្សានូវវប្បធម៌ទៀមទម្លាប់ប្រពៃណីជាតិខ្មែរ ដោយបានខ្នះខ្នែងផ្តួចផ្តើមគំនិតរួបរួមសាមគ្គីគ្នាជាធ្លុងមួយក្នុងការបង្កើតបានជាទីក្រុងខ្មែរមួយជាផ្លូវការ (Cambodia Town) នៅលើទឹកដីសហរដ្ឋអាមេរិក ។

នាយករដ្ឋមន្ត្រីខ្មែររូបនេះបានបង្ហាញនូវមោទនភាពសម្រាប់ប្រជារាស្ត្រ និងព្រះរាជាណាចក្រកម្ពុជា

តំណាងអភិបាលរដ្ឋCalifornia និងក្រុមចៅសង្កាត់ក្រុង Long Beach

អ្នកតំណាងរាស្ត្រសហរដ្ឋអាមេរិក ធ្វើពិធីសច្ចាប្រណិធានចំពោះសមាជិកក្រុងខ្មែរ

ក៏ដូចជាសម្រាប់ប្រជាពលរដ្ឋនានានៅក្នុងតំបន់ និងពិភពលោកដែលក្រុងខ្មែរត្រូវបានទទួលស្គាល់ជាផ្លូវការនៅសហរដ្ឋអាមេរិកក្នុងការជំរុញការកសាងសមិទ្ធផលសង្គមជាច្រើនក្នុងក្រុងខ្មែរ សំដៅអភិវឌ្ឍន៍ទីក្រុងដែលជាមាតុភូមិទី2របស់ខ្មែរឱ្យមានការរីកចម្រើនលើគ្រប់វិស័យ និងមានឈ្មោះបោះសំឡេងក្នុងពិភពលោក ។

នៅក្នុងពិធីនោះភ្ញៀវជាខ្មែរបានសម្តែងការខកចិត្តចំពោះអ្នកមុខអ្នកការដែលរៀបចំពិធីពុំបាននិយាយភាសាកំណើតរបស់ខ្លួន ក្នុងខណៈដែលអង្គការក្រុងខ្មែរមួយនេះបានថ្លែង និងរៀបរាប់ពីតម្លៃវប្បធម៌ ប្រពៃណីខ្មែរ សំដៅឱ្យភ្ញៀវបរទេសយល់ដឹងពីអត្តសញ្ញាណជាតិខ្មែរនោះ ។ ភ្ញៀវខ្មែរចូលរួមបានអន់ចិត្ត និងរិះគន់ថា អ្នកដឹកនាំក្រុងខ្មែរ និងគណៈកម្មការរៀបចំពិធីមិនឱ្យតម្លៃភាសាជាតិខ្មែរខ្លួនឯង។

ចំណែកប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភាជាតិកម្ពុជា ទាំងលោក ជា ស៊ីម និងលោក ហេង សំរិន ទៀត គឺលោក Edwar Royce ដែលតែងតែនិយាយមិនបណ្តាក់មាតិរិះគន់រដ្ឋាភិបាលខ្មែរពីបញ្ហារំលោភសិទ្ធិមនុស្ស ការជួញដូរស្ត្រី និងកុមារ បានសម្តែងការរីករាយ និងឱ្យតម្លៃអតីតជនភៀសខ្លួនដែលបានរួចផុតជីវិតដោយការសម្លាប់រង្គាលផ្តាច់ផ្តិលជីវិតខ្មែរអស់ជិត2លាននាក់ ក្នុងរបបខ្មែរក្រហម ហើយបានកំពុងរស់នៅលើទឹកដីអាមេរិកដែលជាមាតុភូមិទី2ថាបានកំពុងនាំដំណើរជីវិតរស់នៅក្នុងសុភមង្គល ដោយគ្មានភាពតក់ស្លុត និងក្តីរន្ធត់ពីអតីតកាលប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនៃរបបវាលពិឃាតនោះ ។

លោកតំណាងរាស្ត្រ Royce បានបញ្ជាក់ថា ក្នុងនាមជាអនុប្រធាននៃគណៈកម្មាធិការសិទ្ធិមនុស្ស និងកិច្ចការបរទេសរបស់រដ្ឋសភាអាមេរិកយើងសូមកោតសរសើរ និងឱ្យតម្លៃពីការវិវឌ្ឍន៍របស់បងប្អូនខ្មែរ និងសហគមន៍ខ្មែរ ដែលនាំគ្នាកសាងមូលដ្ឋានសេដ្ឋកិច្ចតំបន់របស់ខ្លួនរហូតលេចចេញនូវក្រុងខ្មែរជាផ្លូវការឡើងបាន ។

តាមស្ថិតិមិនទាន់ផ្លូវការបានបង្ហាញថា មានបងប្អូនខ្មែរនៅទីក្រុង Long Beach មានចំនួនជាង1សែននាក់ ដោយសហគមន៍ខ្មែរតាមបណ្តោយផ្លូវ Anaheim, ផ្លូវលេខ10 និងផ្លូវ Pacific Coast Hwy បានបង្ហាញនូវអត្តសញ្ញាណជាតិឱ្យបរទេសបានយល់ដឹងក្នុងរយៈពេល3ទសវត្សរ៍មកនេះ តាមរយៈសហគមន៍ខ្មែរមានសមាគម, អង្គការសហគមន៍, វត្តអារាម, ផ្សារខ្មែរ, ម្ហូបខ្មែរនៅតាមភោជនីយដ្ឋាននានា, កន្លែងលក់ DVD, CD ដែលអួតបង្ហាញពីជីវិតប្រចាំថ្ងៃរបស់ខ្មែរនៅឯមាតុភូមិកំណើតអក្សរខ្មែរឆ្លាក់ ឬពាក់តាមហាងជំនួញ ជំនឿ សាសនា វប្បធម៌ប្រពៃណីខ្មែរត្រូវបានបង្ហាញនៅតាមពិធីធំៗ បានបញ្ជាក់ក្នុងសារលិខិតដោយបង្ហាញមោទនភាពមួយរបស់ជាតិយើងដែលបានបង្កើតក្រុងខ្មែរជាផ្លូវការនៅតំបន់វប្បធម៌ និងពាណិជ្ជកម្មនាទីក្រុង Long Beach ដោយសូមវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់អង្គការក្រុងខ្មែរដែលបានចូលរួមចំណែកប្រកបដោយស្មារតីស្នេហាជាតិក្នុងបុព្វហេតុបម្រើប្រទេសជាតិ និងប្រជាពលរដ្ឋកម្ពុជា ។

អ្នកតំណាងរាស្ត្រអាមេរិកដែលជាគូប្រឆាំងលោក ហ៊ុន សែន លោក Dana Rohra bacher បានថ្លែង "ខ្ញុំបានស្គាល់ពីតម្លៃខ្មែរ សហគមន៍ខ្មែរ តាមរយៈម្ហូបអាហារខ្មែរ ខ្ញុំគាំទ្រឱ្យបានជោគជ័យកើតមានក្រុងខ្មែរ ដោយចង់ឃើញនូវសហគមន៍ Long Beach រក្សាបានការរស់រានៃជីវិតផ្តុំទៅដោយវប្បធម៌ខ្មែរ តំបន់សេដ្ឋកិច្ចរឹងមាំដោយជោគជ័យតាមបណ្តោយផ្លូវ Anaheim ការរួបរួមគ្នាកសាងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចវប្បធម៌ខ្មែរមួយនេះ" ។

រីឯអ្នកតំណាងរាស្ត្រអាមេរិកដ៏មានឥទ្ធិពលម្នាក់

អ្នកស្រី សិទ្ធា សាន ប្រធានសមាគមក្រុងខ្មែរ ថ្លែងទៅកាន់ភ្ញៀវដែលចូលរួម

នៅតាមបណ្តាប្រទេសនានានឹងអាចធ្វើបានដូចមានតំរូសហគមន៍ខ្មែរនៅក្រុង Long Beach ដើម្បីលើកតម្កើងវប្បធម៌ជាតិខ្មែរ ពង្រីកតំបន់សេដ្ឋកិច្ច ។

ចំណែកបងប្អូនខ្មែរមួយចំនួនបានរិះគន់ និងមើលឃើញថា រយៈពេល3ឆ្នាំក្រុងខ្មែរគ្មានអ្វីបែកនោះទេ។

សហគមន៍ខ្មែរ Long Beach ចម្រុះទៅដោយជំពូកមនុស្សនិស្សិត បញ្ញវន្តខ្មែរក្នុងទសវត្សរ៍ឆ្នាំ1970 អ្នកធ្វើការ អ្នកជំនួញ អ្នករស់នៅ ដោយទទួលលុយរដ្ឋដែលជាអតីតជនភៀសខ្លួននៅក្នុងទសវត្សរ៍ឆ្នាំ1980 និងអ្នកជនអន្តោប្រវេសន៍ទសវត្សរ៍ឆ្នាំ1990 និងឆ្នាំ2000 ។ មូលដ្ឋានខ្មែរ Long Beach នេះដែរក៏ជាសមរភូមិអ្នកធ្វើ និងអ្នកគាំទ្រនយោបាយគណបក្សនៅប្រទេសកម្ពុជាគួរឱ្យចាប់អារម្មណ៍ផងដែរ ពួកមេដឹកនាំប្រទេសកម្ពុជា មេដឹកនាំគណបក្សនយោបាយតែងតែចាប់យកក្រុងខ្មែរ Long Beach ក្នុងបរិបទទាក់ទាញយកកម្លាំងបងប្អូនខ្មែរគាំទ្រដល់គោលនយោបាយខ្លួនរួមទាំងការជួយគាំទ្រថវិកាផងដែរ ។

កម្លាំងសេដ្ឋកិច្ច និងជីវភាពខ្មែរនៅក្រុង Long Beach ក៏ជាដង្ហើមសេដ្ឋកិច្ចចំពោះជាតិខ្លួននៅឯប្រទេសកម្ពុជាមួយផងដែរតាមរយៈការផ្ញើលុយកាក់ទៅជួយបងប្អូននៅឯនាយសមុទ្រនោះ ។ ហើយចំណែកឯការសាបព្រោះផ្នែកលទ្ធិប្រជាធិបតេយ្យ និងការយល់ដឹងពីសិទ្ធិមនុស្សតាមរយៈច្បាប់ទម្លាប់នៃការរស់នៅរបស់បងប្អូនខ្មែរនៅអាមេរិកក៏បានឆ្លុះបញ្ចាំងឱ្យទៅដល់ញាតិសន្តានរបស់ពួកគាត់នៅកម្ពុជាកំពុងតែបានយល់ជ្រួលជ្រាបពីស្ថានការណ៍នយោបាយរបស់អ្នកដឹកនាំកម្ពុជា ។

តថភាពនៃគំហើញដែលស្តែងចេញមកនេះឥទ្ធិពលបងប្អូនខ្មែរ នៅក្រៅប្រទេសបានជំរុញនូវទឹកព្រះទ័យរបស់ព្រះមហាក្សត្រខ្មែរ សម្តេចព្រះបរមនាថ សីហមុនី បានផ្ញើព្រះរាជសារថ្លែងអំណរព្រះគុណគោរពស្រឡាញ់ និងឱ្យតម្លៃខ្មែរនៅក្រៅប្រទេសពិសេសខ្មែរនៅអាមេរិកដែលបាននាំឈ្មោះខ្មែរ វប្បធម៌ ប្រពៃណីខ្មែរឱ្យពិភពលោកបានស្គាល់ ដោយបន្តរក្សាអត្តសញ្ញាណជាតិខ្មែរឱ្យរស់រវើកនៅលើឆាកអន្តរជាតិ ៕

ប្រវត្តិព្រះអាចារ្យ "ហែម ច្បៅវ"

(តមកពីលេខមុន)

ដោយ : អ៊ុម លឿម

•••ក្រោយមកអ្នកទោសនយោបាយក៏ត្រូវបានបារាំងបញ្ជូនទៅព្រៃនគរតាមកប៉ាល់ដើម្បីកាត់ទោស ។

យោងតាមឯកសារមួយដែល "ខ្មែរប៉ុស្តិ៍" ទទួលបាន១សរសេរថា កាលនោះស្តេចខ្មែរគ្មានគិតពីបញ្ហាប្រទេសជាតិទេ គឺគិតតែសប្បាយនឹងស្រីញីរាំរែកពេញចន្ទឆាយា ពុំជួយឈឺឆ្អាលពួកបាតុកសោះ បែរជាចូលដៃនឹងពួកបារាំង ហើយជេរប្រមាថកាតទាន ដល់ព្រះសង្ឃថា "អាត្រដៅលបួសបំផ្លាញបាយ" ។ ក្នុងឯកសារដដែលបានសរសេរទៀតថា :"លោកតាម្នាក់មានប្រសាសន៍ថា ស្តេចសុវាម្រិត បានដឹកប្រាក់សុទ្ធ និងមាសទៅសូកប៉ាន់បារាំងច្រើនណាស់ ដើម្បីឱ្យកូនខ្លួនបានសោយរាជ្យ ។ បារាំងក៏យល់ព្រមហើយដាក់ខសន្យាកុំឱ្យស្តេចនឹងឡើងគ្រងរាជ្យថ្មីនោះ ភ្លេចបារាំង ដូច្នេះហើយបានជាស្តេចអង្គនោះនឹកគុណបារាំងមិនភ្លេច" ។

ការកាត់ទោសប្រហារជីវិត

នាវាបានស្រែកលាកំពុងផែភ្នំពេញ រួម១ ចំនួនបីដង រួចទម្លាក់កន្ទុយ ហើយថ្វើដំណើរត្រឿន១ទៅនៅលើនាវា លោកអាចារ្យ ហែម ច្បៅវ, លោក ប៉ាច ឈឺន, លោក នួន ឌួង និងអ្នកទោសឯទៀត ជើងជាប់ច្រវាក់ ដោយសម្លឹងមើលទៅកំពូលវត្តឧណ្ណាលោមសំដែងនូវក្តីអាឡោះអាល័យមាតុភូមិ មិនចង់ឃ្លាតឆ្ងាយទេ ។ លោកស្តាយខានបានរស់នៅជាមួយជនរួមឈាមជាទីស្នេហា! ស្តាយខានបានឃើញមុខឧបាសក ឧបាសិកា ដែលតែងតែពិគ្រោះគ្នាអំពីបញ្ហាសាសនា ។ លោកអាចារ្យកំសត់បានលើកដៃទាំងពីរប្រណម្យ ហើយពោលពាក្យខ្សឹប១ថា : ខ្ញុំម្ចាស់សូមថ្វាយបង្គំលា ហើយមិនដឹងថ្ងៃណាបានជួបវិញទេ! សូមព្រះបារមីជួយថែរក្សាព្រះទូលបង្គំផង! ទូលបង្គំចង់រស់តទៅទៀត ដើម្បីស្រង់ប្រទេសដែលលិចលង់ច្រើនឆ្នាំមកហើយនោះ ។ ឱកន្លែងដ៏មនោរម្យ! ដែលធ្លាប់ផ្តល់នូវវិជ្ជា និងសេចក្តីសុខគ្រប់បែបយ៉ាង! ខ្ញុំមិនភ្លេចអ្នកទេ! ទោះបីអាចោរព្រៃសម្លាប់ខ្ញុំ ក៏វិញ្ញាណក្ខន្ធខ្ញុំហើរមកទីនេះវិញដែរ ។ សូមអ្នកអភ័យទោសដល់ខ្ញុំ ដែលមិនបានចូលលាដល់កន្លែងព្រោះខ្ញុំជាមនុស្សមានទោស មិនអាចមានសេរីភាពធ្វើអ្វីកើតតាមចិត្តចង់! តែខ្ញុំមិនតូចចិត្តឡើយនូវទោសកំហុសដែលបារាំងវាចោទ ដោយសារតែខ្ញុំស្រឡាញ់ជាតិ, សាសនា ខ្ញុំស្លាប់ក៏ស្លាប់ចុះឱ្យតែជាតិសាសនារស់... ។

កប៉ាល់បានបើកមកដល់មុខវាំង ញ៉ាំងចិន្តាលោកគ្រូអាចារ្យ ហែម ច្បៅវ និងមិត្តភក្តិឯទៀតឱ្យក្តៅឆេះឆួលហួសប្រមាណ ។ លោកមានការស្អប់ខ្ពើមរបបរាជានិយម ដែលលោកអាចារ្យបានចោទថាមានភាពឃោឃៅ គ្មានពិចារណាកេរិ្តធម៌, គ្មានគិតប្រជារាស្ត្រក្រីក្រដែលពួកបរទេសសង្កត់សង្កិន។ ការឈឺចិត្ត, ការភ្ញាក់រឭករបស់លោកអាចារ្យ ហែម ច្បៅវ មានតាំងពីលោកនៅជាសិស្សសាលាបាលីជាន់ខ្ពស់មេ្លះ ។ លោកជាមេបដិវត្តន៍ដ៏ឧត្តមម្នាក់ ដែលគេកម្រនឹងបានជួប ។

បន្តិចក្រោយមកនាវាចម្បាំងដឹកអ្នកទោសនេះក៏មកដល់មុខសាលាបាលីជាន់ខ្ពស់ ដែលជាទីបណ្តុះវិជ្ជារបស់លោក ។ លោកសម្លឹងកំពូលសាលាដោយក្តីចុកណែនឱរ៉ា ហើយបង្កើតសម្លេងតាមខ្យល់ទៅដល់សិស្សកំសត់ថា : ឱសិស្សជាទីស្នេហាអើយ! តើអ្នកបានត្រូណាបង្ក្រៀនអ្នកឯទៀត បើខ្ញុំត្រូវបរទេសដឹកទៅប្រហារជីវិតដូច្នេះ! ខ្ញុំមិនចង់ឃ្លាតអ្នកទេ! អ្នកជាសិស្សប្រកបដោយធម៌ ចេះស្រឡាញ់វិជ្ជាដូចចិត្តគ្រូបង្ហែងប្រាថ្នា ! ថ្ងៃនេះខ្ញុំឃ្លាតពីអ្នកហើយ ! ចូលអ្នកខំសិក្សាជាមួយគ្រូថ្មីឱ្យមែនទែន បើអ្នកពិតជាស្រឡាញ់ខ្មែរមែន ! ចូរអ្នកខំរក្សាកិត្តិយស សាសនាយើងកុំឱ្យសាបសូន្យណា ! ខ្ញុំគ្មានអីផ្ញើមកអ្នកក្រៅពីបណ្តាំមួយម៉ាត់នេះទេ គឺបើអ្នកស្រឡាញ់ខ្ញុំ ទុកខ្ញុំជាគ្រូត្រូវខំរៀន ហើយរំដោះប្រទេសជាតិឱ្យបានឯករាជ្យឡើង ។ ជយោ សាលាបាលី ! ខ្ញុំលាហើយ លាទាំងមិនបានឃើញមុខអ្នករាល់គ្នា ! លាហើយកន្លែងធ្លាប់រៀន ធ្លាប់ជំនុំគ្នា ! លាហើយមាតុភូមិជាទីស្នេហាស្នើនឹងជីវិត ! លាហើយញោមញាតិដែលធ្លាប់ស្រឡាញ់រាប់អានគ្នាឥតមានហ្មង... លាហើយទីក្រុងកំសត់ដែលត្រូវគេសង្កត់សង្កិន ! លាហើយប្រិយមិត្តដែលគិតប្រយោជន៍ជាតិ...! លាទាំងអាល័យនិងឈឺចិត្តជាទីបំផុត ! ។

ចំណែកលោក នួន ឌួង និងលោក ប៉ាច ឈឺន ក៏មានដុំទុក្ខដូចជាលោកគ្រូ ហែម ច្បៅវ ដែរ ។ លោក ប៉ាច ឈឺន ក្តី, លោក នួន ឌួង ក្តី, លោកគ្រូអាចារ្យ ហែម ច្បៅវ ក្តី និងអ្នកឯទៀតក្តី គ្មានស្តាយស្រណោះជីវិតទេ តែសោកស្តាយខានបានបន្តសកម្មភាព ដើម្បីរំដោះជាតិឱ្យរួចពីនឹមដែកអាណានិគមនិយមបារាំងឱ្យរួចសិន ។ ការគិតវែងឆ្ងាយនូវបញ្ហាជាតិទាំងនេះហើយ ដែលធ្វើឱ្យជលនេត្រវិរបុរសខ្មែរយើងហូរដោយមិនដឹងខ្លួន ។ លោកទាំងនេះពុំបានសន្ទនាគ្នាតាមសម្លេងទេ គឺគ្រាន់តែសន្ទនាគ្នាតាមខ្សែភ្នែកប៉ុណ្ណោះ។

ដំណើរនាវាទៅមុខជានិច្ច ឥតបានគិតដល់មនុស្សដែលមានទុក្ខហួសព្រំដែនសោះឡើយ ។ ទេសភាពដងទន្លេពីភ្នំពេញទៅព្រៃនគរមានសភាពក្រៀមក្រំសង៉ំស្ងៀមឈឹងហាក់ដូចជាឈរគោរពវិរបុរស ដែលបារាំងដឹកទៅកាត់ទោសនាក្រុងព្រៃនគរ ក្នុងពេលខាងមុខនេះ ។

សភាពស្ងប់ស្ងាត់នេះរឹងរឹតតែទាញព្រលឹងវិរជនយើងឱ្យរំភើបឥតឧបមា ។

នៅពេលដែលនាវាបើកហួសព្រំប្រទល់ដែនខ្មែរ លោក នួន ឌួង បានបន្លឺសម្លេងទៅកាន់លោកអាចារ្យ ហែម ច្បៅវ ដោយញ័រ១ : ព្រះតេជគុណ យើងឃ្លាតពីមាតុភូមិយើងហើយ !។ អើលោក ! នេះជាការធម្មតារបស់យើងទេ... សូមកុំទោមនស្សអី !។ ពិតមែនហើយ ! តែព្រលឹងខ្ញុំវាមិនព្រមដាច់អាល័យពីខ្មែរយើងសោះ ។ អើ ! ខួនខ្ញុំក៏យ៉ាងនោះដែរ ! ខ្ញុំមិនអាចភ្លេចជាតិយើងបានទេ ទោះបីបារាំងសម្លាប់ចោលក៏ដោយ ក៏ខ្ញុំមិនគិតដែរ គឺខ្លាចតែប្រទេសយើងពុំបានសេរីភាពប៉ុណ្ណោះ ។ លោក នួន ឌួង ឆ្លើយតបវិញ : មិនអីទេ ខ្មែរយើងក្លាក់រលីកខ្លះហើយព្រះតេជគុណ !។ កំពុងសន្ទនាគ្នាជាប់មាត់ ស្រាប់តែស័ក្តិពីរបារាំងដើរមកជិត ហើយស្រែកថា : ឈប់ជជែកគ្នាទេ ! រៀបចំខ្លួន ឡើងដល់ផែឥឡូវហើយ។ អ្នកទោសទាំងអស់ក៏ធ្វើតាមបារាំងនោះ ។

ដល់ព្រៃនគរថ្ងៃបន្តទ្រុងមួយបានមកដឹកអ្នកទោសយកទៅដាក់គុកធំ ។ អំពើយង់ឃ្នងនៅគុកព្រៃនគរ ក៏ដូចជាគុកនៅភ្នំពេញដែរ ។ ពួកអ្នកចូលថ្មីតែងតែទទួលថ្នាំខ្លាំងពីអ្នកទោសដៃឆ្អើតគ្រប់ៗគ្នា។ អំពើប្រាស់ចាកមនុស្សធម៌នេះ កើតឡើងដោយសារពួកបារាំងវាបង្កើតឡើង កុំឱ្យអ្នកទោសត្រូវនឹងអ្នកទោស គឺជានយោបាយបំបែកបំបាក់ ដើម្បីស្រួលត្រួតត្រាទៅទៀត ។ ខ្មែរអ្នកទោសខ្លះដោយបារាំងកាន់ជើង ខ្លួនក៏ឡើងដៃ វាយធ្វើបាបជាតិឯងគ្មានគិតមុខគិតក្រោយអ្វីសោះ ។ ពេលចូលទៅដល់លោក នួន ឌួង ត្រូវបានមេគុកម្រួតគុកព្រៃនគរវាយទាត់ធាក់រហូតសន្លប់បាត់ស្មារតី លែងដឹងខ្លួនទៅចំពោះមុខអ្នកទោសជាច្រើន ព្រោះតែលោកឆ្លើយថា : "ក្បត់បារាំង" ។ អំពើនេះធ្វើឱ្យកល្យាណមិត្តលោកអាណិតស្ទើរភ្លេចស្មារតី ។

(តទៅលេខក្រោយ)

ART OF WELLNESS CENTER

Art of Wellness
"Integrating Holistic Healthcare for the Mind, Body, and Spirit."
(215)305-2238
www.artofwellnesscenter.com

មន្ទីរសុខភាព "Art Wellness" ទទួលព្យាបាលបញ្ហាផ្លូវចិត្ត និងធ្វើទៅតាមទម្លាប់ និងជំនឿរបស់លោកអ្នក ដោយប្រើរបៀបបច្ចេកទេសអាស៊ី និងបច្ចេកវិទ្យាបស្ចឹមប្រទេស ។

ចំពោះលោកអ្នកមានការលំបាកណាមួយដូចចំណុចខាងក្រោម :

• ធ្លាក់ទឹកចិត្ត	DEPRESSION	• ឈឺខ្លួនប្រាណគ្រប់កន្លែង	PAIN MANAGEMENT
• ការថប់អារម្មណ៍	ANXIETY	• មានវិបត្តិក្នុងគ្រួសារ	FAMILY ISSUES
• ភាពតានតឹង	STRESS	• ការញៀន និងអ្វីមួយ	ADDICTION ISSUES
• មានកំហឹងច្រើន	ANGER MANAGEMENT	• សុខភាពស្ត្រី	WOMEN´S HEALTH

•Allergy Testing & Elimination
•Weight Managerment for Adult & Children
•Diabetes
•High Blood Pressure
•High Cholesterol Level Issue
•រកប្រតិកម្មនឹងធាតុអ្វីមួយ ហើយបំបាត់វាចេញ
•ត្រួតត្រាទម្ងន់សម្រាប់ចាស់និងក្មេង
•ទឹកនោមផ្អែម
•លើសសម្ពាធឈាម
•លើសកាឹត កូលេស្តេរ៉ុល
•Insomnia (Difficulty Sleeping)
•Facial Acupuncture (reduce wrinkles)
•Nutrition Consultation (Free)
•Genetic Testing
•Feeling Tired & Weak
•We Accept AETNA & United Healthcare
•ដេកមិនលក់
•ប្រើម្ជុលព្យាបាលលើផ្ទៃមុខ (បន្ថយភាពជ្រីវជ្រួញ)
•ពិគ្រោះពីម្ហូបអាហារ (មិនយកកំរៃ)
•ធ្វើតេស្តអំពីពូជ
•អស់កម្លាំង មិនស្រួលខ្លួន
•យើងទទួលយក AETNAនឹង UNITED HEALTHCARE

ទទួលព្យាបាលគ្រប់វ័យ

ទទួលព្យាបាលត្រចៀយ	TREATMENT TYPE
• ប្រើម្ជុលឥតថ្នាំ	• Acupuncture
• ចាប់សរសៃ	• Acupressure
• ចិត្តវិទ្យា	• Psychotherapy
• យោគ/ភាវនា	• Yoga/ Meditation

វេជ្ជបណ្ឌិតនឹងអ្នកជំនាញការមានបទពិសោធន៍ច្រើនឆ្នាំនៅប្រទេសចិន និងនៅសហរដ្ឋអាមេរិក ។
សូមអញ្ជើញទូរស័ព្ទ ឬមកមន្ទីរពេទ្យសុខភាពយើងខ្ញុំ ដើម្បីពិគ្រោះវិធីព្យាបាល

ART OF WELLNESS CENTER
647 BAINBRIDGE STREET,
PHILADELPHIA, PA 19147
215-305-2238
ភាសាខ្មែរទាក់ទង ប៊ុន វ៉ាត់ : 267-242-8526

ដោយ : តឹម ភឿន (តពីលេខមុន)

•••ប្រទេសកម្ពុជាដោយសារតែភ្លេចខ្លួននឹងកោះសន្តិភាពរបស់ខ្លួននៅក្បែរភ្នក់សង្រ្គាមនៃប្រទេសជិតខាង មានយួន និងលាវនោះ ក៏ត្រូវគេអូសទំលាក់ឱ្យធ្លាក់ចុះក្នុងសង្រ្គាមមួយដែលគ្មានបានគ្រោងទុកជាមុន។ ទ័ពបរទេសចូលមកឈ្លានពានស្រុកយើងសោះ តែខ្មែរយើងបែកបាក់គ្នា ក៏ត្រូវបានគេយល់ថា ជាសង្រ្គាមស៊ីវិល សង្រ្គាមក្នុងស្រុកទៅវិញ។ មើលទៅសង្រ្គាមនេះហួសនិស្ស័យនឹងដោះស្រាយទៅហើយ មានតែខំសម្លាប់ខ្មែរគ្នាឯងឱ្យអស់ ដើម្បីបំពេញចិត្តចៅហ្វាយរឿង។ ខ្លួន។ នេះជាក្តីទុក្ខដែលខ្មែរធ្លាប់បានជួបច្រើនសារមកហើយក្នុងប្រវត្តិសាស្ត្រដ៏ជូរចត់របស់ខ្លួន។ វិរៈ លង់ក្នុងការគិតមិនចេះចប់មិនចេះហើយ ស្តាយស្រណោះប្រទេសជាតិដែលកំពុងតែបានសុខសាន្ត ភ្លេចខ្លួនតែបន្តិចត្រូវគេអូសទាញឱ្យធ្លាក់ចុះក្នុងជ្រោះជ្រៅរីខ្លួនលែងរួចតែម្តង។

គេឆ្ងល់ខ្លាំងណាស់ថា ហេតុអ្វីអ្នកដឹកនាំប្រទេសកម្ពុជា មិនឆ្លៀតយកឱកាសប្រទេសជិតខាងច្បាំងគ្នា ខ្លួនត្រូវតែរកស្មៀតការពារខ្លួនធ្វើយ៉ាងណាកុំឱ្យសង្រ្គាមហូរចូលមករកប្រទេសខ្លួន ហើយខំពង្រីកពង្រឹងសេដ្ឋកិច្ចប្រទេសខ្លួនឱ្យបានរឹងមាំ ធ្វើឱ្យប្រទេសខ្លួនក្លាយជាសម្បូរសប្បាយទាក់ទាញប្រទេសទាំងឡាយឱ្យចូលមកធ្វើជំនួញជួញដូរជាមួយប្រទេសខ្លួនតាមច្បាប់អន្តរជាតិត្រឹមត្រូវ។ ឆ្ងល់ថាហេតុអ្វីបានទៅបើកធ្វើជំនួញតាមរបៀបមួយ ដែលនាំគ្នាប្រមូលយកលុយក្លែងក្លាយចូលមកពេញស្រុក ហើយឱ្យគេមកប្រមូលជញ្ជូនយកអស់អង្ករស្រូវ ត្រីសាច់ជ្រូកមាន់ទាចេញទៅអស់ពីនគរ ធ្វើឱ្យរបស់របរឡើងថ្លៃកប់ពពក រាស្ត្រក្រីក្ររកកលអត់បាយក្រហាយទឹកយ៉ាងណាឯង? វិរៈ ធ្លាប់តែមានមោទនភាពពីអត្តមគ្គទ្វេសក័របស់ប្រទេសជាតិខ្លួន ដែលមានភាពឆ្ងៃសវៃបញ្ឆៀសប្រទេស និងប្រជារាស្ត្រខ្លួនឱ្យផុតពីសង្រ្គាមបង្ហូរឈាមឱ្យបានសុខសន្តិភាព ឮតែសម្លេងភ្លេងវាំវង់ជំនួសសម្លេងផ្ទុះគ្រាប់រំសេវ។ មិនស្មានទាល់តែសោះថា អ្នកដឹកនាំកំពូលរបស់ជាតិទៅណាបាត់អស់ទៅ ទើបបណ្តោយទុកឱ្យប្រទេសជាតិចាញ់ប្រៀបមិត្តល្អរបស់ខ្លួន ហើយយកអង្ករទៅដូរយកអង្កាមយ៉ាងនេះទៅវិញ? ។

បើចង់កសាងឱ្យប្រទេសជាតិរុងរឿង ប្រទេសកម្ពុជាមានថាមពលគ្រប់គ្រាន់ ដើម្បីអនុវត្តឈានទៅរកគោលដៅនេះយ៉ាងងាយបំផុត ប្រសិនបើប្រទេសនេះមានអ្នកដឹកនាំត្រឹមត្រូវ ប៉ុនប្រសប់ប្រកបទៅដោយទឹកចិត្តស្នេហាជាតិមុះមុត ហើយប្តូរផ្តាច់ដើម្បីបុព្វហេតុនេះ។ វិរៈ យល់ដូច្នោះ ព្រោះតាមការសិក្សាក្នុងសាលាក្តី ការសិក្សាតាមការអានឯកសារនានាឃើញថា ប្រទេសកម្ពុជាសម្បូរដោយទ្រព្យសម្បត្តិធម្មជាតិ មានរ៉ែមាស ស្ពាន់ ដែក សំណប៉ាហាំង ត្បូងពេជ្រ រ៉ែ ធ្យូងថ្ម ប្រេងកាត... ទ្រព្យសម្បត្តិធម្មជាតិទាំងនេះមានរាយនៅសឹងតែគ្រប់ខេត្តនៃប្រទេស និងផ្ទៃសមុទ្រយើង ចុះហេតុអ្វីមិនគិតគូរកមធ្យោបាយប្រើប្រាស់សម្បត្តិធម្មជាតិទាំងនោះ ដើម្បីកសាងប្រទេសជាតិរបស់ខ្លួន។ បើគិតដល់ប្រាង្គប្រាសាទនានា ខ្មែរពិតជានគរមួយមានសំណាងឯកក្នុងលោកដែលគ្មានប្រទេសណាមានដូច។ ប្រសិនមានអ្នកគ្រប់គ្រងប៉ុនប្រសប់ កុំថាឡើយដល់សម្បត្តិធម្មជាតិនានា គ្រាន់តែប្រាង្គប្រាសាទមួយមុខនេះក៏អាចជួយប្រទេសកម្ពុជា ឱ្យរកបានចំណូលរូបិយប័ណ្ណអន្តរជាតិយ៉ាងសន្ធឹកសន្ធាប់ ដើម្បីយកមកកសាងប្រទេសរបស់ខ្លួនយ៉ាងគ្រប់គ្រាន់បំផុត។ ប្រាង្គប្រាសាទទាំងនោះ ជាប្រភពសម្បត្តិធម្មជាតិមួយដែលមិនចេះរីងស្ងួត ប្រសិនបើយើងចេះថែរក្សាការពារអភិរក្សត្រឹមត្រូវនោះ។ ហើយបើគេបូករួមសម្បត្តិធម្មជាតិខ្មែរទាំងអស់មក គេឃើញថាប្រទេសកម្ពុជាជាប្រទេសមួយមានធនធានមហាសាល ដែលអាចជួយឱ្យប្រទេសកម្ពុជា ក្លាយជាប្រទេសសម្បូរសប្បាយលើសពីប្រទេសស្តេចប្រេងកាតនានាលើពិភពលោកទៀតផង ប្រជានុរាស្ត្រនឹងមានប្រាក់ប្បៀវត្សរ៍ត្រប់ៗគ្នា សុខមាលភាពសង្គមពិតជាបានប្រសើរជាងប្រទេសនានាលើពិភពលោកមិនខាន។ បានយ៉ាងនេះហើយគិតតែពីជម្រុញផ្នែកសិក្សាធិការឱ្យបានល្បឿនទៅមុខ ឱ្យអនាគតនៃមនុស្សជំនាន់ក្រោយក្លាយជាអ្នកចេះដឹងគ្រប់ៗគ្នា មិនចាញ់បោកងាយ។ ក្រោមការបោកបញ្ឆោតនៃអ្នកដទៃ ឬប្រទេសដទៃ។ ទាល់តែចេះដឹងគ្រប់ៗគ្នាទើបប្រជារាស្ត្រទាំងអស់មិនបណ្តោយឱ្យបុគ្គលមួយភាគតូចមានចំណេះដឹងបន្តិចបន្តួច ដឹកនាំប្រទេសជាតិផ្តាច់មុខដើរទៅក្នុងផ្លូវខុសបាន។ ប្រទេសជាតិមិនអាចដឹកនាំតាមការនឹកឃើញពីមួយថ្ងៃទៅមួយថ្ងៃឡើយ វាត្រូវមានផែនការទិសដៅបត់បែនទៅតាមស្ថានការណ៍ពិភពលោក។ ប្រទេសជារបស់រួមនៃយើងជាប្រជាពលរដ្ឋខ្មែរទាំងអស់គ្នា យើងត្រូវមានភារកិច្ច និងសិទ្ធិស្មើៗគ្នាក្នុងការរក្សាការពាររួមគ្នាឱ្យប្រទេសនេះស្ថិតក្នុងសភាពសប្បាយរុងរឿង ហេតុនេះហើយការសិក្សាចំណេះដឹងត្រូវតែបានប្រព្រឹត្តឡើងឱ្យបានភាគច្រើនជាអតិបរមានៃប្រជាពលរដ្ឋ ដើម្បីជួយគ្នារក្សាការពារប្រទេសនេះមានលំនឹងនៅក្នុងក្តីសុខដុមរមនា និងនិរន្តរភាពតរៀងទៅអស់កប្បកាលសម្រាប់កូនចៅជំនាន់ក្រោយៗទៀត។ អ្នកដឹកនាំប្រទេសជាតិត្រូវតែហ៊ានប្តូរផ្តាច់លះបង់ខ្ពស់ ហ៊ានស្លាប់ខ្លួនដើម្បីឱ្យជាតិរស់ ហ៊ានលះបង់ប្រយោជន៍ផ្ទាល់ខ្លួនហើយប្តូរផ្តាច់ដើម្បីប្រយោជន៍ជាតិ។ បើគ្មានចរិតលក្ខណៈនេះទេ គួរតែកុំដឹកនាំប្រទេសជាតិ ព្រោះពិតជាដឹកនាំប្រជារាស្ត្រទៅរកការអត់ឃ្លានទុក្ខសោក វេទនាពុំខានឡើយ ទោះសម្បត្តិធម្មជាតិមហាសាលប៉ុណ្ណាក៏ដោយ ។ (សូមរង់ចាំអានបន្តនៅលេខក្រោយទៀត)

(សូមលោកអ្នកមេត្តាអភ័យទោសចំពោះការអាក់ខានផ្សាយនូវអត្ថបទដែលមានចំណងជើងថា "ទឹកតែ៣ពែង" ឬ Three Cups of Tea សូមលោកអ្នករង់ចាំអាននៅលេខក្រោយបន្តទៀត)

កិច្ចសម្ភាសន៍រវាងខ្មែរប៉ុស្ដិ៍ជាមួយប្រធានអង្គការសម័្ពន្ធអប់រំខ្មែរ

ដោយ : អ៊ុម លឿម

•••មានមនុស្សតិចតួចណាស់ដែលអង្គការមនុស្សធម៌ខ្មែរមួយដែលមានទីស្នាក់ការរបស់ខ្លួនក្នុងសហរដ្ឋអាមេរិក តែបើគេនិយាយឈ្មោះ វ៉ិលលី ប្រធានអង្គការប្រមូលថវិកាសម្រាប់ជួយដល់ជនក្រីក្រនៅឯប្រទេសកម្ពុជាវិញ គេប្រាកដជាស្គាល់ឈ្មោះនេះជាពុំខាន់ ។ ថ្មីៗកន្លងមកនេះ លោក វ៉ិលលី អ៊ុយ Willie Oy ប្រធានអង្គការ "សម័្ពន្ធអប់រំខ្មែរ" បានទទួលជោគជ័យដ៏មហាសាលក្នុងដំណើរបេសកកម្មគ្បៀងគរប្រមូលថវិកាសម្រាប់ជួយសម្រួលដល់ជនក្រីក្រ, ជនទុរគត... នៅទីក្រុងហ៊ីឡាដែលហ្សៀ នៃរដ្ឋផែនស៊ីវ៉ែនស៊ើរ សហរដ្ឋអាមេរិក ។

ខាងក្រោមនេះជាខ្លឹមសារនៃកិច្ចសម្ភាសន៍មួយរវាង "ខ្មែរប៉ុស្ដិ៍" និងលោក វ៉ិលលី :

-តើលោកអាចជម្រាបមិត្តអ្នកអានបានទេថា អ្វីជាសកម្មភាពដែលលោកកំពុងធ្វើពេលបច្ចុប្បន្ននេះ ?

- វ៉ិលលី : ជម្រាបតាមត្រង់ទៅសកម្មភាពដែលខ្ញុំធ្វើសព្វថ្ងៃនេះ ទី១ គឺចង់ជួយបងប្អូនខ្មែរយើង ដែលមានភាពក្រីក្រ ពីព្រោះរូបខ្ញុំផ្ទាល់កាលពីជំនាន់ ប៉ុល ពត ក៏ជួបនូវហេតុការណ៍ទាំងអស់ហ្នឹងដែរ អញ្ចឹងហើយបើយើងមានឱកាសយើងត្រូវជួយវិញ ហើយនេះជាផ្នែកមួយនៃការធ្វើបុណ្យដាក់ទាន ។ និយាយឱ្យចំទៅខ្ញុំមានជំនឿលើព្រះពុទ្ធសាសនា ដែលចូលចិត្តធ្វើបុណ្យ ។

-ខ្មែរប៉ុស្ដិ៍ : តើអង្គការរបស់លោកមានឈ្មោះអ្វីពិតប្រាកដនោះ ?

- វ៉ិលលី : "សម័្ពន្ធអប់រំខ្មែរ" ជាភាសាអង់គ្លេស មានន័យថា "CAMBODIAN EDUCATION NETWERK" ។

- ខ្មែរប៉ុស្ដិ៍ : តើសម័្ពន្ធអប់រំខ្មែរហ្នឹង មានការទាក់ទាញខាងផ្នែកសិក្សាធិការពលរដ្ឋខ្មែរ នៅក្នុងប្រទេសដែរឬទេ ?



- វ៉ិលលី : បាទទាក់ទងទាំងអស់ បើចង់ដឹងច្បាស់ទាល់តែឆែកនៅក្នុងវិបសាយរបស់យើងខ្ញុំ គឺ www.cambodianeducationalnetwork.org អញ្ចឹងគឺគាត់អាចដឹងពីគោលការណ៍ និងគម្រោងទៅអនាគត ថាយើងចង់ធ្វើអ្វីខ្លះនោះ។

(សូមលោកអ្នករង់ចាំអានកិច្ចសម្ភាសន៍រវាង "ខ្មែរប៉ុស្ដិ៍" និងលោក វ៉ិលលី នៅលេខក្រោយបន្តទៀត)

តមកទំព័រទី០១ សហរដ្ឋអាមេរិកបញ្ចប់សង្រ្គាមផ្ទាល់ដែរ...

នៅលើសម្តីនេះ លោកប្រធានាធិបតី នឹងផ្លាស់ប្តូរយុទ្ធវិធីធ្វើសង្រ្គាមដោយផ្ទាល់ដៃហើយប្រគល់ឱ្យជនជាតិអ៊ីរ៉ាក់ ធ្វើដោយខ្លួនឯងវិញម្តង ពេលនោះ គឺបន្ទាប់ពី ៧ឆ្នាំ ដែលសហរដ្ឋអាមេរិកផ្តើមវាយលុកចូលអ៊ីរ៉ាក់ ហើយបន្តទៅទៀត សហរដ្ឋអាមេរិក និងទុកទាហាន ៥០.០០០នាក់ សម្រាប់តាមបង្ហាត់ហ្វឹកហ្វឺនយោធាអ៊ីរ៉ាក់ ។ ការទទួលខុសត្រូវរបស់សហរដ្ឋអាមេរិក គឺបើកសមរភូមិផ្នែកផ្លូវទូតវិញម្តង ។

ចាប់ពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៣ ដែលសម័្ពន្ធមិត្តសហរដ្ឋអាមេរិក វាយសំរុកទៅអ៊ីរ៉ាក់ ហើយដែលសហរដ្ឋអាមេរិក នឹងបញ្ចប់ទៅវិញនាថ្ងៃទី៣១ ខែសីហា ២០១០ នោះគឺអាមេរិកាំងបានធ្វើសង្រ្គាមផ្ទាល់ដៃចំនួន៦៧៥ថ្ងៃស្មាប់ឃុទ្ធជនអស់ ៤,៤១៣នាក់ មានរបួស ៣១៨៧៤នាក់ (ឃុទ្ធជនពីរដ្ឋផែនស៊ីវ៉ែនាមានស្លាប់១៥៦នាក់) ឃុទ្ធជនជាគ្រូបង្ហាត់មាន ៥ម៉ឺននាក់ ហើយចំនួនឃុទ្ធជនចម្បាំងដែលបានដកតាំងពីលោកប្រធានាធិបតី អូបាម៉ា ឡើងកាន់អំណាចរហូតដល់ថ្ងៃទី៣១ ខែសីហា នោះនិងមានចំនួនត្រប់៤ម៉ឺននាក់ ។ សហរដ្ឋអាមេរិកបានចំណាយលើទាហានដែលរក្សាទុកនៅអ៊ីរ៉ាក់ ក្នុង១ឆ្នាំ ៣៤ម៉ឺនក្នុងម្នាក់ៗ ។

លោក អូបាម៉ា បានបន្តថា "ការលំបាកជឿនោះ គឺយើងមិនបានឃើញលទ្ធផលបញ្ចប់នៅការបរិច្ចាគរបស់សហរដ្ឋអាមេរិក នៅប្រទេសអ៊ីរ៉ាក់ តែយើងពុំបានធ្វើអ្វីខុសនៅឡើយទេ ការខិតខំធ្វើតាមសន្យារបស់យើងនៅអ៊ីរ៉ាក់ បានប្តូរពីការប្រឹងប្រែងរបស់កងទ័ពទៅការប្រឹងប្រែងរបស់ក្រុមស៊ីវិលដឹកនាំដោយក្រុមការទូតតែប៉ុណ្ណោះ ។

លោក ខូលិន ផ្លូវែល រដ្ឋលេខាធិការក្រសួងការបរទេសឆ្នាំ២០០៣ បានដឹកនាំចម្បាំងសហរដ្ឋអាមេរិកជាមួយនឹងសម័្ពន្ធមិត្តជាង៣០ប្រទេសមានជាអាទិ : អាហ្វហ្គានីស្ថាន, អាល់បានី, អូទ្រីស, អាហ្សែបាយហ្សង់, កូឡុមប៊ីយ៉ា, ប៊ុលគារី, សាធារណរដ្ឋឆេកូ, ដាណឺម៉ាក, អែលសាលវ៉ាឌ័រ, អេរីត្រា, អេសតូនីយ៉ា, អេថូពី្យ, ជកជ្យា, ហុងគ្រី, អ៊ីតាលី, ជប៉ុន, កូរ៉េខាង ត្បូង, ឡាតវីយ៉ា, លីជូនីយ៉ា, ម៉ាសេដូនីញ៉ា, ណេឌែឡង់, នីការ៉ាគ្វា, ហ៊ីលីពីន, ប៉ូឡូញ, រ៉ូមានី, ស្លូវ៉ាគីយ៉ា, អេស្ប៉ាញ, តួគី, អង់គ្លេស និង អូបេគីស្ថាន ។

សម្រាប់ប្រទេសអ៊ីរ៉ាក់តែមួយ សហរដ្ឋអាមេរិកបានប៉ាន់ថា បានចាយប្រាក់ដុល្លារហូតដល់ខែកញ្ញា ២០១០ នេះ អស់ ៥០០ ប៊ីលីយ៉ុងហើយ ៕ "ខ្មែរប៉ុស្ដិ៍"

A.B.C MONEY TRANSACTION, INC

$ ក្រុមហ៊ុនផ្ញើប្រាក់ A.B.C

តម្លៃសំរាប់ផ្ញើទៅស្រុកខ្មែរ

		ភ្នំពេញ	តាមខេត្ត
ផ្ញើ $100	យកកម្រៃ	$4.50	$5.50
$200	យកកម្រៃ	$9.00	$11.00
$300	យកកម្រៃ	$13.50	$16.50
$500	យកកម្រៃ	$16.00	$17.00
$1000	យកកម្រៃ	$25.00	$26.00
$1500	យកកម្រៃ	$35.00	$36.00
$2000	យកកម្រៃ	$42.00	$43.00
$2200	យកកម្រៃ	$46.00	$47.00

សូមកុំភ្លេចទាក់ទងការិយាល័យក្រុមហ៊ុន ABC ដែលនៅជិតលោកអ្នក ប្រសិនបើមានបំណងចង់ផ្ញើប្រាក់ទៅស្រុកខ្មែរ ឬក៏ទូរស័ព្ទមកយើងតាម

នៅរដ្ឋ VIRGINIA សូមទាក់ទង

ABC MONEY TRANSATION ,INC.

8 locations to serve you in Virginia

- 6757 Willson Blvd.-Ste.#25 Tel : 703.534.2600
- 4291 Holland Rd-Ste.#111 Tel : 757.474.9400
- 10428 Ridgefield Pkwy Tel : 804-740-2454
- 2519 W . Mercury Blvd . Tel : 757.265.6305
- 23520 Overland Dr. Tel : 703.661.6666
- 6314 Rigsby Rd. Tel : 804.288.2988
- 7252 Arlingston Blvd . Tel : 703.641.0778
- 6217 W. Broad St. Tel : 804.288.6988

ARIZONA
- 4215 N 19th Ave. . Tel : 602.266.6744

GEOERGIA
- 4897 Buford Hwy. Ste. 202. Tel: 770.457.7888

ILLINOIS
- 4871 N. Broadway . Tel :773.989.7332

MASSACHUSETTE
- 996 Dorchester Ave. Tel:617.825.9380
- 1365-1377 Dorchester Ave. -Ste.4,Froor 1 .Tel : 617.265.4600

MINNESOTA
- 2718 Nicollet Ave . S.- Ste. 102 B
- Tel : 612.871.4731
- 6350 Brooklyn Blvd . Tel : 763.503.3947

NORTH CAROLINA
- 3000 Central Ave. Ste . #9 . Tel : 704-532-4420

OREGON
- 6908 N.E. Sandy Blvd . Tel : 503.281.8088

PHILADFELPHIA
- 5520 . Whitaker Ave. -Unit 2 . Tel : 215.831.9794
- 571 Adams Ave . Ave.#4 . Tel : 215.342.6623

TEXAS
- 1818 E . Pioneer Pkwy. Ste.156 . Tel : 317.461.1461
- 2615 W . Pioneer Pkwy. Ste.136 . Tel : 214.788.2817
- 5302 E . Belknap St.- Ste.D6 . Tel : 817.831.4836
- 3538 W . Walnut St. Tel : 972.272.2253
- 11205 Bellaire Blvd . Tel : 281.561.6600
- 10909 Scarsdale Blvd . Tel : 281.481.2700
- 13480 Veterans Memorial Dr.-Ste. F2. Tel: 281.587.0807

WASHINTON STATE
- 766 S.38th St,. Tel : 253.475.2847
- 3818 S.Graham St.-Ste. C Tel : 206.721.2070

ក្រុមហ៊ុនធន្ទួលផ្ញើប្រាក់ទៅកម្ពុជា

ABC ជាក្រុមហ៊ុនផ្ញើប្រាក់តែមួយគត់នៅស្រុកខ្មែរ ដែលមានការប្រគល់ប្រាក់ដល់ផ្ទះ

- ស្របច្បាប់
- រហ័សទាន់ចិត្ត
- ធានារ៉ាប់រង និងជូនប្រាក់ទៅដល់ផ្ទះ
- កំរៃផ្ញើថោកជាងកន្លែងដទៃ

ក្រៅពីការផ្ញើប្រាក់ក្រុមហ៊ុនមានលក់

PHONE CARD និង PINLESS សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ដែលផលិតដោយក្រុមហ៊ុន ABC ផ្ទាល់ មានគុណភាពល្អ ហើយជាពិសេស CARD របស់យើងនឹងទុកបានរហូត មិនអស់កំណត់កាលឡើយ (NEVER EXPIRED) ។

ត្រូវការអ្នកសហការ (AGENTS) ជាមួយយើងទូទាំងសហរដ្ឋអាមេរិក និងបានទទួលប្រាក់ចំណូលយ៉ាងខ្ពស់ !

ព័ត៌មានបន្ថែមសូមទាក់ទង CHET THACTHER តាមទូរស័ព្ទ និងអាស័យដ្ឋានខាងក្រោម :

ABC MONEY TRANSATION, INC
12019 Garden Grove Blvd., Ste.#204
Garden Grove , CA 92843
chesterthatcher@yahoo.com

Office : 714-590-8740 Fax : 714-590-8776
Cell: 714-603-3509 Toll Free : 1-877-939-0110

ឌី ឃែមបូឌា ដេលី The Cambodia Daily

ដំណឹងថ្មៃសរុបពីតារាសាអង់គ្លេស អត្ថបទជ្រើសរើស និងចងក្រងការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌី ឃែមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី០៦ ខែសីហា ឆ្នាំ២០១០

Visitor Arrivals Up 12.39% Through June

By Hul Reaksmey
THE CAMBODIA DAILY

The number of visitor arrivals to Cambodia increased 12.39 percent in the first half of the year compared to the same period last year, according to statistics released yesterday by the Tourism Ministry.

From January to June, more than 1.2 million people visited Cambodia, with 166,000 coming in June, an increase of 18.21 percent that month compared to last year, according to the statistics. The increases follow dismal 1.7 percent growth in 2009 as the economic crisis struck the pocketbooks of travelers around the world.

Kong Sopheareak, the director of the Tourism Ministry's statistics department, said that improvements in roads, as well as recovery from the global economic crisis, have also affected growth.

"I think that the tourism sector will continue to grow as the [economic] crisis moves away," he said. "The proper facilitation of transportation has contributed to the growth of tourism."

He added that development of tourism sites in the northern provinces should contribute to the draw of Cambodia, and that Cambodia must continue to promote new activities and destinations.

Luu Meng, president of the Cambodian Hotel Association, said he expected the growth to continue, as bookings at hotels have increased by as much as 20 percent for October, November and December compared to last year.

"I think the high season looks quite positive, not only in our hotel but other hotels in Phnom Penh," he said. "More people are booking ahead; it's different than last year."

Ho Vandy, co-chair of the Government-Private Sector working group on tourism, said Cambodia must continue developing tour packages to draw visitors, and efforts to increase the number of flights is paying off.

According to the statistics, visitors who arrived by air increased 13.65 percent and account for more than 52 percent of entries.

"We must demand to have tour packages with proper airfare to attract tourists," he said.

(Additional reporting by Tim Sturrock)

ការមកដល់របស់ភ្ញៀវទេសចរកើនឡើង ១២,៣៩ ភាគរយ

ដោយ ហ៊ុល រស្មី
THE CAMBODIA DAILY

យោងតាមស្ថិតិដែលចេញកាលពីម្សិលមិញ ដោយក្រសួងទេសចរណ៍បានឱ្យដឹងថា ចំនួននៃការមកដល់របស់ភ្ញៀវទេសចរក្នុងប្រទេសកម្ពុជា បានកើនឡើង ១២.៣៩ភាគរយក្នុងរយៈពេល៦ខែ ដំបូងនៃឆ្នាំនេះ បើប្រៀបធៀបទៅនឹងអំឡុងពេលដូចគ្នាកាលពីឆ្នាំទៅ ។

យោងតាមស្ថិតិនេះបានឱ្យដឹងថា ចាប់ពីខែមករា ដល់ខែមិថុនា មានភ្ញៀវជាង១.២លាននាក់ បានមកទស្សនកិច្ចប្រទេសកម្ពុជា ដោយភ្ញៀវចំនួន១៦៦.០០០នាក់បានមកដល់ក្នុងខែមិថុនា ជាការកើនឡើងចំនួន១៨.២១ភាគរយនៅក្នុងខែនោះ បើធៀបទៅនឹងឆ្នាំមុន ។ កំណើននេះបានកើតឡើងបន្ទាប់ពីមានកំណើនតិចតួចចំនួន១.៧ភាគរយក្នុងឆ្នាំ២០០៩ ខណៈដែលវិបត្តិសេដ្ឋកិច្ចបានប៉ះពាល់ដល់ប្រភពហិរញ្ញវត្ថុរបស់ភ្ញៀវទេសចរណ៍នៅជុំវិញពិភពលោក ។

លោក គង់ សុធារ: ប្រធាននាយកដ្ឋានស្ថិតិរបស់ក្រសួងទេសចរណ៍បានមានប្រសាសន៍ថា ការធ្វើឱ្យប្រសើរឡើងនូវផ្លូវថ្នល់ និងការរើបឡើងវិញ ពីវិបត្តិសេដ្ឋកិច្ចពិភពលោក ក៏មានឥទ្ធិពលដល់កំណើននេះដែរ ។

លោកបានមានប្រសាសន៍ថា "ខ្ញុំគិតថា វិស័យទេសចរណ៍និងបន្តការកើនឡើងពេលដែលវិបត្តិ (សេដ្ឋកិច្ច) កន្លងផុតទៅ ។ ការសម្របសម្រួលឱ្យបានសមស្របនូវការដឹកជញ្ជូនក៏បាននាំមកនូវកំណើនទេសចរណ៍" ដែរ ។

លោកបានបន្ថែមថា ការអភិវឌ្ឍទីកន្លែងទេសចរណ៍ក្នុងបណ្តាខេត្តភាគខាងជើង និងចូលរួមចំណែកដល់ភាពទាក់ទាញរបស់កម្ពុជា ហើយថា ប្រទេសកម្ពុជាត្រូវតែបន្តផ្សព្វផ្សាយអំពីសកម្មភាពនិងទីកន្លែងទេសចរណ៍ថ្មីៗ ។

លោក លូ ម៉េង ប្រធានសមាគមសណ្ឋាគារកម្ពុជា បានមានប្រសាសន៍ថា លោករំលឹកថា កំណើននេះនឹងបន្ត ពីព្រោះការកក់នៃឯសណ្ឋាគារបានកើនឡើងដល់២០ភាគរយសម្រាប់ខែតុលា ខែវិច្ឆិកា និងខែធ្នូ បើប្រៀបធៀបទៅនឹងឆ្នាំមុន ។

លោកបានមានប្រសាសន៍ថា"ខ្ញុំគិតថា រដូវសំបូរភ្ញៀវទេសចរមានភាពវិជ្ជមានបំផុត មិនត្រឹមតែនៅក្នុងសណ្ឋាគាររបស់យើងប៉ុណ្ណោះទេ ប៉ុន្តែសណ្ឋាគារផ្សេង១ទៀត នៅក្នុងក្រុងភ្នំពេញដែរ ។ មានមនុស្សជាច្រើនកំពុងកក់ទុកមុន វាខុសពីឆ្នាំទៅ " ។

លោក ហូរ វ៉ាន់ឌី សហប្រធានក្រុមការងារទទួលបន្ទុកទេសចរណ៍ផ្នែករដ្ឋ-ឯកជន បានមានប្រសាសន៍ថា ប្រទេសកម្ពុជាត្រូវតែបន្តការអភិវឌ្ឍបញ្ចប់ទេសចរណ៍របស់យើង ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ ហើយកិច្ចប្រឹងប្រែងដើម្បីបង្កើនចំនួនជើងហោះហើរកំពុងតែឱ្យផល ។

យោងតាមស្ថិតិនេះ បានឱ្យដឹងថា ភ្ញៀវទេសចរដែលបានមកដល់តាមផ្លូវអាកាសបានកើនឡើង ១៣.៦៥ភាគរយ ហើយស្មើនឹងចំនួនជាង៥២ភាគ រយនៃការចូលមកប្រទេសនេះ ។

លោកបានថ្លែងថា "យើងត្រូវតែទាមទារឱ្យមានកញ្ចប់ទេសចរណ៍ជាមួយនឹងតម្លៃសមរម្យ ដើម្បីទាក់ទាញភ្ញៀវទេសចរ" ៕

(រាយការណ៍បន្ថែមដោយ : Tim Sturrock)

Cholera Cases Since November Pass 500 Mark

By Alice Foster
and Chhorn Chansy
THE CAMBODIA DAILY

The number of confirmed cholera cases nationwide since November has now risen above 500, according to new statistics posted to the Health Ministry's communicable disease control department website.

Although ministry officials could not be reached for comment yesterday, the statistics show that 501 people tested positive for cholera across 18 provinces between November and July 27, while one person has died.

New cholera cases have been emerging for more than six months, but they are in relatively small clusters and not part of one large outbreak, said Dr Nima Asgari, public health specialist at the World Health Organization.

"We are seeing a few cases here and there.... The outbreaks have been stopped from becoming a much bigger [problem]," Dr Asgari said, noting that a large escalation in the number of cholera cases is unlikely at this point.

Still, any diagnosis of cholera is a cause for concern and should prompt a response, said Jan-Willem Rosenboom, country team leader of the World Bank's Water and Sanitation Program.

"I call 500 a significant number, and obviously even if it is only 10 cases something must be done to address this," Mr Rosenboom said.

Dr Sin Somuny, executive director of Medicam, said yesterday that the government has improved its response to cholera since the disease first broke out in November, mobilizing rapid response teams and setting up a hotline for patients to call.

"The situation has also improved on the government side," Dr Somuny said. "Previously they did not even say that it was cholera and used to just say acute watery diarrhea."

Cholera still poses a significant threat to Cambodia and, at least in Ratanakkiri province, the disease is becoming endemic, said Alex Marcelino, program manager for NGO Health Unlimited.

"It is not only an emergency coming from time to time, but something we are seeing to be endemic and which keeps reoccurring," Mr Marcelino said.

Some donors only release funds in an emergency situation, which makes it difficult for NGOs to fill the gap in operation costs facing the Ratanakkiri provincial health department, he said. Mr Marcelino called on the government to make an official statement about the extent of the cholera outbreaks.

"We cannot access resources unless a more forthright declaration is given by the national government," he said.

ករណីជំងឺអាសន្នរោគចាប់តាំងពីខែវិច្ឆិកាមក ឡើងលើស ៥០០ ករណីហើយ

ដោយ Allice Foster និង អ៊ុច ចាន់ស៊ី
THE CAMBODIA DAILY

យោងតាមស្ថិតិដែលដាក់តាមវិបសាយរបស់នាយកដ្ឋានគ្រប់គ្រងជំងឺឆ្លងនៃក្រសួងសុខាភិបាល បានឱ្យដឹងថា ចំនួននៃករណីជំងឺអាសន្នរោគដែលត្រូវបានបញ្ជាក់អះអាងនៅទូទាំងប្រទេសចាប់តាំងពីខែវិច្ឆិកាមកនោះ ពេលនេះបានកើនឡើងលើស ៥០០ ករណីហើយ ។

បើទោះបីជាកាលពីម្សិលមិញ គេមិនអាចទាក់ទងក្រុមមន្ត្រីក្រសួងសុខាភិបាលដើម្បីសុំការអត្ថាធិប្បាយបានក៏ដោយ ក៏ស្ថិតិនោះបង្ហាញថា មនុស្សចំនួន ៥០១នាក់ ដែលបានធ្វើតេស្តឃើញជំងឺអាសន្នរោគនៅទូទាំងខេត្តចំនួន១៨ ចន្លោះពីខែវិច្ឆិកា ថ្ងៃទី២៧ ខែកក្កដា រីឯមនុស្សម្នាក់បានស្លាប់ ។

លោកវេជ្ជបណ្ឌិត នីម៉ា អាសហ្គារី ជាអ្នកឯកទេសខាងសុខាភិបាលសាធារណៈនៃអង្គការសុខភាពពិភពលោក បានមានប្រសាសន៍ថា ករណីជំងឺអាសន្នរោគថ្មីៗបានឆាបឆេះកំពុងលេចឡើងអស់រយៈពេលជាង៦ខែមកហើយ ប៉ុន្តែបើប្រៀបធៀបទៅវាមានទ្រង់ទ្រាយតូចប៉ុណ្ណោះ មិនមែនជាការផ្ទុះឡើងចំដុំនោះទេ ។

ដោយធ្វើការគូសបញ្ជាក់ថា ការកើនឡើងច្រើននៃជំងឺអាសន្នរោគទំនងជាមិនអាចនៅពេលនេះនោះ វេជ្ជបណ្ឌិត នីម៉ា អាសហ្គារី មានប្រសាសន៍ថា "យើងឃើញមានករណីតិចតួចប៉ុណ្ណោះ... ។ ការផ្ទុះឡើងនៃជំងឺនេះត្រូវបានរាំងមិនឱ្យរាលដាលការតែចំឡើង១ទៀតទេ" ។

លោក ជែន វិលឡេម រ៉ូសេនប៊ូម ជាមេដឹកនាំនៃក្រុមកម្មវិធីទឹកស្អាតនិងអនាម័យរបស់ធនាគារពិភពលោកប្រចាំនៅប្រទេសកម្ពុជា បានមានប្រសាសន៍ថា ទោះជាយ៉ាងណាការធ្វើរោគវិនិច្ឆ័យឃើញជំងឺអាសន្នរោគ គឺជាមូលហេតុដែលបង្កឱ្យមានការព្រួយបារម្ភ និងគួរតែមានការឆ្លើយតបភ្លាម១។

លោក ជែន វិលឡេម រ៉ូសេនប៊ូម បានមានប្រសាសន៍ថា "៥០០ ករណីក៏ជាចំនួនច្រើនដែរ ហើយដាក់ស្តែងបើទោះជាមានតែ១០ ករណីក៏ដោយក៏ត្រូវមានវិធានការដើម្បីដោះស្រាយបញ្ហានេះដែរ" ។

លោកវេជ្ជបណ្ឌិត ស៊ីន សុមុនី ជានាយកប្រតិបត្តិនៃក្រុមហ៊ុនឱសថ Medicam បានមានប្រសាសន៍កាលពីម្សិលមិញថា រដ្ឋាភិបាលបានធ្វើឱ្យការឆ្លើយតបរបស់ខ្លួនចំពោះជំងឺអាសន្នរោគមានភាពប្រសើរឡើងហើយចាប់តាំងពីជំងឺនេះបានចាប់ផ្តើមផ្ទុះឡើងជាលើកដំបូងនៅក្នុងខែវិច្ឆិកាមក ដោយបានប្រើប្រាស់ក្រុមឆ្លើយតបរហ័ស និងបង្កើតខ្សែទូរស័ព្ទពិសេសមួយសម្រាប់ឱ្យអ្នកជំងឺទូរស័ព្ទប្រាប់ ។

លោកវេជ្ជបណ្ឌិត ស៊ីន សុមុនី បានមានប្រសាសន៍ថា "ស្ថានភាពក៏បានប្រសើរឡើងហើយដែរនៅខាងរដ្ឋាភិបាល" ។ "កាលពីដំបូងពួកគេមិននិយាយថា វាជាជំងឺអាសន្នរោគទេ ហើយធ្លាប់ត្រឹមតែនិយាយថាជាជំងឺរាកអូសស្រួចស្រាវប៉ុណ្ណោះ" ។

លោក អេឡិច ម៉ាសេលីណូ ជានាយកកម្មវិធីរបស់អង្គការគ្រូពេទ្យគ្មានព្រំដែន ដែលជាអង្គការក្រៅរដ្ឋាភិបាលបានមានប្រសាសន៍ថា យ៉ាងហោចណាស់នៅក្នុងខេត្តរតនគីរីជំងឺនេះកំពុងក្លាយជាជំងឺរាតត្បាតទៅហើយ ។

លោក អេឡិច ម៉ាសេលីណូ បានមានប្រសាសន៍ថា "វាមិនមែនគ្រាន់តែជាភាពអាសន្នមួយដែលកើតឡើងម្តងម្កាលនោះទេ ប៉ុន្តែវាជាជំងឺមួយដែលយើងកំពុងមើលឃើញថា មានការរាលដាល និងដែលចេះតែបន្តកើតឡើងជាងដែរ" ។

លោកបានមានប្រសាសន៍ថា ម្ចាស់ជំនួយមួយចំនួនបញ្ចេញមូលនិធិតែនៅក្នុងភាពស្ថានភាពបន្ទាន់តែប៉ុណ្ណោះ ដែលធ្វើឱ្យមានការពិបាកសម្រាប់អង្គការក្រៅរដ្ឋាភិបាលនានាក្នុងការបំពេញចន្លោះខ្វះខាតនៅក្នុងការចំណាយទៅលើការធ្វើប្រតិបត្តិការដែលមន្ទីរសុខាភិបាលខេត្តរតនគីរីកំពុងប្រឈម ។ លោក អេឡិច ម៉ាសេលីណូ បានអំពាវនាវឱ្យរដ្ឋាភិបាលធ្វើសេចក្តី ថ្លែងការណ៍ជាផ្លូវការមួយពី វិសាលភាពនៃការផ្ទុះជំងឺអាសន្នរោគនេះ ។

លោកបានមានប្រសាសន៍ថា "យើងមិនអាចទទួលបានធនធានទេប្រសិនបើរដ្ឋាភិបាលមិនប្រកាសឱ្យបានត្រង់ៗ ជាងមុននោះទេ" ៕

ជំនាញខាងធ្មេញរបស់អ្នកជាមួយយើង

ពេទ្យថែរក្សាធ្មេញប្រចាំគ្រួសារ

FAMILY DENTAL CARE
AT
SMILE CARE CENTER

626 Snyder Avenue. Philadelphia, Pa 19148

យើងខ្ញុំអាចបកប្រែភាសាខ្មែរជូនលោកអ្នក សូមទាក់ទងជាមួយ ឈ្មោះ រ័ន ហេង និងជា លែនតារ ដើម្បីណាត់ពិនិត្យ

WE SPEAK CAMBODIAN. PLEASE CONTACT :
MALY CHHORN & CHEALEN TAV 215-391-4100

Children and Adults Welcome

- Exams
- Root Canals
- Extractions
- Cleanings
- Braces
- Dental Implants

We accept all types of insurance including Medicare & Medicaid
PLEASE CALL TO MAKE YOUR APPOINTMENT TODAY !
(215) 391-4100

យើងទទួលយកគ្រប់ប្រភេទ អ៊ិនសួរិន ដោយរាប់ទាំងម៉េឌីឃែ និងម៉េឌីឈេដ ផង សូមទូរស័ព្ទរកយើងខ្ញុំ នៅថ្ងៃនេះ ដើម្បីណាត់ពិនិត្យនូវលេខ **(215) 391-4100**

Penn Asian Senior Services PASSi

PASSi ជាសមាគមជួយចាស់ជរា និង ជនពិការ

សមាគមយើងខ្ញុំមានអ្នកថែរក្សាជាជនជាតិខ្មែរដែលអាចមកដែលរក្សាចាស់ជរា និង ជនពិការ

សេវាកម្មត្រូវយកកំរៃផ្តល់ជូនអតិថិជន

- មកជួបនៅគេហដ្ឋានតាមពេលកំណត់
- ជួយរៀបចំម្ហូបអាហារ និងការបរិភោគ
- ជួយរំលឹកពេលដែលត្រូវពិសារ និងប្រើប្រាស់ថ្នាំ
- ជួយក្នុងពេលងូតទឹក
- ជួយក្នុងការសំអិតសំអាង
- ជួយរៀបចំ និងសំអាតគេហដ្ឋាន
- ជួយបោក និងអ៊ុតសំលៀកបំពាក់
- មានអ្នកកំដរក្នុងការនិយាយលេង
- ជំនួយខាងផ្នែកអនាម័យ
- ជួយទិញម្ហូបអាហារ និងសំលៀកបំពាក់
- ជួយថែរក្សាសមាជិកក្នុងគ្រួសារ
- នៅមានជាច្រើនបន្ថែមទៀត

បើលោក លោកស្រីត្រូវការជំនួយសំរាប់សកម្មភាពរស់នៅប្រចាំថ្ងៃដូចបានរៀបរាប់ខាងលើនេះ សូមទាក់ទងមកលេខទូរស័ព្ទ **215-572-1234** ។
ម្យ៉ាងទៀត បើលោកអ្នកនាងដែលថែទាំមនុស្សចាស់ជរា ជាឪពុកម្តាយ ឬជីដូនជីតា នៅក្នុងបន្ទុក អាចនឹងទទួលប្រាក់បៀវត្សបានទៀតផង ។ សូមអរគុណ !

DRANOFF ASSOCIATES
Attorneys at Law

"ដ្រាណុហ្វ អាសូស៊ីយេត (DRANOFF ASSOCIATE) គឺជាមណ្ឌលការពារតាមផ្លូវច្បាប់ ដែលធ្វើការប្រកបដោយភក្តីភាព ដើម្បីតំណាងឱ្យអ្នករងគ្រោះ ដែលមានរបួសរូបរាងកាយ ។

ស្ទីវិន ដ្រាណុហ្វ (STEVEN DRANOFF) គឺជាមេធាវីនៅសាលាក្តីមានបទពិសោធន៍យ៉ាងខ្ពស់ខាងសេវាច្បាប់ ៣៥ឆ្នាំ ។

យើងធ្វើការដោយយកកំរៃពីការងារដែលប្រគល់ឱ្យ លោកអ្នកមិនចាំបាច់ចេញថ្លៃចំណាយអ្វីមុននឹងលោកអ្នកទទួលប្រាក់សងពីមុខរបួសលោកអ្នកនោះទេ ។

ជំនួយខាងផ្លូវច្បាប់អាចផ្តល់ជូនជាភាសា ស្បានីស ខ្មែរ វៀតណាម កូរ៉េ និង ចិន ។

● **របួសលើរាងកាយ :** គ្រោះថ្នាក់រថយន្ត, ឡានឈូល "សិបគា", ឡានត្រឹក, តាក់ស៊ី, ជិះកង់, ថ្មើរជើង, រអិលដួលលើទឹកកក, លើចិញ្ចើមថ្នល់ ឬក្នុងអាគារលក់ទំនិញ, គ្រោះថ្នាក់ដោយបានទិញរបស់ខូចមកប្រើ ឬក៏ឆ្កែខាំ... ។

● **ការប្រហែសក្នុងវិជ្ជាជីវៈ និងសិទ្ធិរបស់អតិថិជន :** ព្យាបាលតាមវិជ្ជាពេទ្យពុំបានត្រឹមត្រូវ, មរណភាពឥតសមហេតុផល, វាយមាយក្នុងការថែទាំមនុស្ស... ។

DRANOFF ASSOCIATES

121 South Broad Street, Suit 1210, Philadelphia, PA 19107
215-732-3333 (phone) 215-732-8059 (fax)
sdranoff@dranofflaw.com

HONG KONG
Super Market

FAMER´S BEST

Newly Renovated. Added new section .
Clean and Improved management !
ទើបនឹងកែលំអរថ្មីឡើងវិញ
-បន្ថែមផ្នែកលក់ថ្មីទៀត ហាងស្អាត ហើយបង្កើនគុណភាពគ្រប់គ្រង
Weekly Sale លក់ចុះថ្លៃរៀងរាល់សប្ដាហ៍

HONG KONG SUPERMARKET (PA) WEEKLY PROMOTION ITEMS

ON SALE PERIOD 8/13/10-8/19/10

79c a LB

99c a LB

49c a LB

$2.99 a LB

99c a LB

$0.49 a LB

$4.99 a Bag

$2.99 a bag

$1.99 a can

3 for $9.99

$6.99 a box

3.49 a Btl

$2.69 a bag

$5.50 each

$1.49 a LB

$2.99 a LB

$1.99 a box

$2.69 a bag

$2.99 a bag

571 ADAMS AVE.PHILADELPHIA, PA 19120
Tel : 215-7281300 Fax : 215-728-1600

OPEN 7DAY
8:00-9:00

- ចំណាយ **$140** ដុល្លារ ទទួលបានអង្ករស្រូវសុទ្ធ **25** ផោន
- ចំណាយ **$100** ដុល្លារ ទទួលបានទូរភ្លេសជូ: ឬមីកញ្ចប់មួយប្រអប់ (តម្លៃ **8.99**)
- ចំណាយ **$25** ដុល្លារ ទទួលបានទឹកសុំណុកមួយដប ឬទឹកត្រីមួយដប ។

តមកទំព័រទី០១

មានអ្វីស្លុកនៅហ្វីឡាដែលហ្សៀ...

II. ប្រធានគណបក្សសិទ្ធិមនុស្សចូលអង្គុយធម៌

លោក កឹម សុខា បានសម្រេចចិត្តចូលទៅបំពេញកិច្ចជាកូនសិស្សរបស់ព្រះធម៌ចំនួន១០ថ្ងៃ ដើម្បីជំរះភាពសៅហ្មង និងការសំអាតចិត្តតាមក្បួនវិប្បសនានៅវត្តម៉ាសាឈូសែត។ នេះជាកម្មវិធីដែលត្រូវផ្តើមនាថ្ងៃពុធ ទី១១ ខែសីហា បន្ទាប់ពីទស្សនកិច្ចប្រកបដោយការរង់ចាំនៅវត្ត "តិចសាស់" និងនៅ "ជចចា" មក។ នៅបន្ទាប់ពីប្រារព្ធវិប្បសនារួចមក លោកប្រធានគណបក្សសិទ្ធិមនុស្ស នឹងចូលរួមជាមួយភរិយាលោកក្នុងមហាសន្និបាតបក្ស ដែលនឹងប្រព្រឹត្តទៅនៅហ្វីឡាដែលហ្សៀ នាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១០ខាងមក ៕

"ខ្មែរប៉ុស្តិ៍"

មានជំនាញខាងទិញ.លក់ជួះ.ពាណិជ្ជកម្ម. វិនិយោគ ហិរញ្ញវត្ថុ ឬជួល
យើងស្វាគមន៍រាល់លោកអ្នកដែលប្តេជ្ញាវិនិយោគ

Vinh Ho, 215-391-9516
Email: vho.realestate@consultant.com
ANCHOR Real Estate Development
320 Oregon Ave, #3B, Philadelphia, PA 19148
Specialize - Buy_Sell_Invest_Finance_Rent ...
Beginner-investors are welcomed!

ឱសថស្ថានចាំងទី២
TANG PHARMACY II
FREE DELIVERY Locally
ចាំងឱសថស្ថានសូមស្វាគមន៍
HYUN TANG, PHARM. D.
ឱសថស្ថានយើងមានទទួលយក Medicare, Medicaid និងInsurance គ្រោះថ្នាក់ចរាចរ និងគ្រោះថ្នាក់នៅកន្លែងធ្វើការនានា។
លោកប្រុស និងអ្នកស្រី អាចទាក់ទងជាភាសាខ្មែរ ដោយកញ្ញា គីម ជូលី (បន្ទាប់ពីម៉ោង ១រសៀល) នៅឱសថស្ថានចាំង ទី២
សូមទាក់ទងហាងថ្នាំយើងខ្ញុំនៅអាស័យដ្ឋាន និងទូរស័ព្ទខាងក្រោម បើលោកអ្នកនៅមានចម្ងល់អ្វីមួយ។

JULIE KIM, MANAGER
Contact After 1 p.m

ចាំង ទទួលវេជ្ជបញ្ជា បន្ទុតម្លៃប័ណ្ណ ចំពោះថ្នាំ (Generic Drug)
តម្លៃ $6.00 ចំពោះថ្នាំសំរាប់ប្រើចំនួន ៣០ ថ្ងៃ
យើងមានថ្នាំចំនួន 500 មុខ ដែលមានគុណភាពប្រសើរ ដូចថ្នាំមានឈ្មោះល្បី (Generic Drugs)

Open: mon- Fri. 9a.m- 6p.m
Sat. 9a.m - 3p.m
5600 North. 5th Street. Philadelphia, PA 19120 Tel: (215) 224-3333 Fax: (215) 224-3363

Liberty Real Estate Associates, LLC

Many years experience in Real Estate deals and investment.
One Stop Shop. Buy-Sell-Manage.
Current Listings:

- 7 Laundromats, 5 restaurants, 2 Vegetable stores
- 11 Properties in Chinatown
- 2 Beer Distributors, one liquor license
- 2 Big Shopping Malls, 3 Stripe Malls
- 99 Cents or up Store, Dry Cleaners, Gas Station, Take Out Restaurant
- Residential Homes in good school district
- Pizza Stores, gift store, small supermarket

Our Agents speak English, Chinese, and Vietnamese

មានបទពិសោធន៍ច្រើនឆ្នាំក្នុងការទិញ លក់ និងវិនិយោគអចលនវត្ថុ
នៅកន្លែងតែមួយមាន: គ្រប់គ្រងផ្ទះ-លក់-ទិញ
នៅបញ្ជីរបស់យើងមាន :
- ហាងម៉ាស៊ីនបោកខោអាវ ៧-អោជនីយដ្ឋាន ៥-ហាងបន្លែ ២
- ម្ចាស់ផ្ទះ ១១កន្លែងនៅឆាយណាថោន
- លក់រាយស្រាបៀ ២-អាជ្ញាប័ណ្ណលក់សុរា ១
- ផ្សារពាណិជ្ជកម្មខ្នាតធំ ២-ប្រជុំផ្សារតូច ១៣
- ហាង ៩៩សេន -បោកគក់សួត ហាងសាំង - អាហារដ្ឋាន
- គេហដ្ឋាននៅជិតសាលារៀនល្អ
- ហាង "ពិតស្កា" ហាងលក់វត្ថុអនុស្សាវរីយ៍-ផ្សារតូច ។

ភ្នាក់ងារយើងនិយាយភាសាអង់គ្លេស ចិន និងវៀតណាម

Richard Li	267-767-7612	Luan To	267-973-0267
Vince Yip	267-808-1878	Hala	609-458-7683
Ron Tran	484-636-8395	David App	215-828-1410
Danny Lin	215-301-7982	Kevin Wong	856-829-0519

924 Arch St. 1st Fl. Philadelphia, Pa 191
Tel : 215-625-4725; 625-726, 472 Fax: 215-625-4728

ហាងជួសជុលឡាន អិន ខេ
NK AUTO
Free Estimate
5901 OXFORD AVENUE. PHILADELPHIA, PA 19149
TEL. 215-533-0163
ជួសជុលទូទៅនឹងសេវាកង់
បើមកធ្វើឡានតាមរយៈពាណិជ្ជកម្មនេះ នឹងទទួលបានបញ្ចុះតម្លៃពិសេស
General Repair & Tire Services
Mention this AD you will receive discount:

Inspection $35.00
Oil Change $20.00
Contact Vannak or Vanney 215-533-0163

NEW GOLDEN PALACE

SEAFOOD RESTAURANT
801-21 Washington Avenue.
Philadelphia, Pa 19147
Tel: 215-627-2822
Business Hours: Monday–Sunday. 10 a.m.--10 p.m.

សូមអញ្ជើញគ្រោងពិធីរបស់លោកអ្នកជាមួយនឹងយើងខ្ញុំ

Plan your next event here!

- *Wedding Reception* ●ពិធីមង្គលការ
- *Birthday Parties* ●បុណ្យខួបកំណើត
- *Business Meetings* ●ប្រជុំការងារជំនួញ
- *Private Parties* ●ពិធីជប់លៀងជាឯកជន
- *Fundraisers* ●បុណ្យវៃអង្គាសប្រាក់
- *We Accept Reservation for Holidays* ●យើងទទួលឱ្យកក់កន្លែងធ្វើពិធីនៅថ្ងៃឈប់បុណ្យទានបាន

យើងបំរើម្ហូប ឌិម ស៊ុម រាល់ថ្ងៃ ពីព្រឹកដល់ល្ងាច

We Serve Dim Sum Daily All Day Long &
Also Try Our Vietnamese Phở
កុំភ្លេច ភ្លក់ "ហ្វ៊ី" វៀតណាមរបស់យើង
From 10 a.m. – 10 p.m.

ពិធីជប់លៀងល្ងាចពិសេស ជាមួយក្រុមគ្រួសារ

ROYAL FAMILY DINNER PACKAGE

សំរាប់៦នាក់-ម្ហូប៧មុខ- $78
DINNER FOR 6 - 7 Entrées $78

1. Vietnamese Spring Roll
2. Sweet Sour Pork Chops
3. Seafood Bean Curd Soup
4. Lobster with Ginger & Scallion
5. Steam Fish
6. House Special Fried Rice
7. Seasonal Fruit

សំរាប់៨នាក់-ម្ហូប៨មុខ- $98
DINNER 8 – 8 Entrées $98

1. Palace Appetizer
2. Shrimp Hot & Sour Soup
3. Baby Claims with Black Bean Sauce
4. Sautéed seafood with Chinese Vegetables
5. Lobster with Ginger & Scallion
6. Steam Fish
7. House Special Lo Mein
8. Seasonal Fruit

សំរាប់១០នាក់-ម្ហូប៩មុខ- $128
DINNER 10 – 9 Entrées $128

1. Fried Shrimp Rolls
2. Salt Baked Shrimp
3. Seafood with Sweet Corn Soup
4. Seafood Bird's Nest
5. Crispy Fried Chicken
6. Double Lobsters with Ginger Scallion
7. Steam/Fried Fish Tilapia
8. House Special Fried Rice
9. Seasonal Fruit

COMPUTER+ LLC

SURVEILLANCE SYSTEM, COMPUTER RETAILER, REPAIR & SERVICES

ចំនាយការខាងថ្លៃសេវាកុំឲ្យខ្ពស់ លក់គ្រឿងកុំឲ្យខ្ពស់
និងតាក់គ្រឿងឥតរើខេត្តសំរាប់ការពារសន្តិសុខ

REMOTE VIEWING
Remote Monitoring, Recording, Controlling through Internet from *anywhere* at *anytime*

Stand-Alone System



PC-Base System



HOME or VACATION

On the ROAD

5709 N. 5th St., Phila, PA 19120 Open: *Mon-Sat; 10am—6:00pm*
Peter Hong Ching * Tel: (215) 276-7000 * Fax: (215) 276-7001
E-mail: peterchng_99@yahoo.com www.computerpluslic.com

Nationwide

Insurance & Financial Service

សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ

We offer Cheap Price for Every Client

យើងធ្វើជូនគ្រប់គ្រៀវដោយតម្លៃទាប

Business Liability Insurance	ធានារ៉ាប់រងជំនួញឃោកអ្នក
Home Insurance	ធានារ៉ាប់រងផ្ទះសម្បែង
Health Insurance	ធានារ៉ាប់រងសុខភាព
Auto Insurance	ធានារ៉ាប់រងរថយន្ត
Life Insurance	ធានារ៉ាប់រងជីវិត

Discount 30% when you purchase
Home & Auto Insurance
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ
ធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8 Philadelphia, PA 19147
Tel: (215) 463-1257 , Fax: (215) 463-2036

មួយរាត្រី... ៣៥ឆ្នាំនៃកងទ័ពអាកាសខ្មែរនៅក្រុងឡុងប៊ិច

ខ្មែរប៉ុស្ដិ៍ : វ៉ានាថ

អ្នកថតរូប : វ៉ាន់ថា ឯល

ឡុងប៊ិច : កាលពីរាត្រីមួយនៅកណ្ដាលទីក្រុងខ្មែរ ឡុងប៊ិច ថ្ងៃទី 10 ខែកក្កដា ឆ្នាំ2010 នៅ ក្នុងពិធីជួបជុំមួយបានបង្ហាញនូវវីរភាពស្នេហាជាតិមាតុភូមិ ការពារកុំឱ្យខ្មាំងសត្រូវឈ្លានពាននាអតីតកាលប្រវត្តិ-សាស្ត្រអំឡុងឆ្នាំ 1970 ។

មនុស្សម្ភាមិនតិចជាង600នាក់ជាអតីតយុទ្ធជននៃកងទ័ពអាកាសខ្មែរ ជាក្រុមគ្រួសារអ្នកស្នាប់ក្នុងអតីតកាលសមរភូមិសង្គ្រាមក្នុងបញ្ជាការដ្ឋានទ័ពអាកាសនេះដែរ បានណាត់ជួបជុំគ្នារំលឹកខួបទី35ឆ្នាំរបស់អង្គភាពមួយនេះ ។

ការជួបជុំមិនថា អ្នកនៅតាមបណ្ដារដ្ឋនានា ក្នុងសហរដ្ឋអាមេរិក, បារាំង, កាណាដា និងពីប្រទេសកម្ពុជាបាននាំគ្នានិយាយរម្លឹកពីអតីតកាលនៃមិត្តរួមអាវុធនៅលើបក្សីស្នាបដែកក្នុងសមរភូមិសង្គ្រាមនាទសវត្សរ៍ឆ្នាំ1970 ។

ឧត្តមសេនីយ៍មេបញ្ជាការនៃកងទ័ពអាកាស ខ្មែរ សូ សាតូ បានថ្លែងចំពោះមុខកូនទាហានរបស់ខ្លួនក្នុងពិធីជួបជុំរម្លឹកខួបឆ្នាំទី35 ដែលជាការជួបជុំធំបំផុតមួយឱ្យដឹងថា ពេលវេលារសាត់ទៅដែលស្ទើរតែមិនជឿគឺ35ឆ្នាំកន្លងទៅហើយ ដែលយើងបានឃ្លាតឆ្ងាយពីគ្នាដែលគួរឱ្យរំជួលចិត្តជាទីបំផុត ។ អនុស្សាវរីយ៍កាលពីនៅក្នុងកងទ័ពអាកាសបានស្ថិតនៅក្នុងអារម្មណ៍យើងជានិច្ច មិនអាចរលុបបានមួយវិនាទីណាឡើយ អ្វីៗដែលកន្លងទៅក្លាយទៅជាប្រវត្តិសាស្ត្រទៅហើយ ប៉ុន្តែយើងគ្រាន់តែចង់រក្សាទុកនូវភស្តុតាង និងសក្ខីកម្មជូនខេមរជនជំនាន់ក្រោយបន្តវេនជាទ័ពអាកាសឱ្យមាន ប្រសិទ្ធភាពអាចការពារដែនអាកាសខ្មែរយើងបាន ដើម្បីរក្សាការពារមាតុភូមិរបស់យើងបន្តទៅទៀត" ។

ឧត្តមសេនីយ៍ សូ សាតូ បានថ្លែងបន្តទៀតថា ឆ្លៀតឱកាសនេះខ្ញុំសូមលំឱនកាយគោរពចំពោះវីរភាពរបស់មិត្តរួមអាវុធដែលបានបូជាជីវិតក្នុងសមរភូមិក្តី ក្នុងរបបខ្មែរក្រហមក្តី និងនៅកន្លែងផ្សេងទៀតក្តី ហើយអំពាវនាវឱ្យអស់លោកទាំងអស់គ្នា ជាសមាជិកទ័ពអាកាសខ្មែរ សូមរក្សាឱ្យបានទូវមូលដ្ឋានគ្រឹះនៃទ័ពអាកាស គឺបន្តការស្រឡាញ់គ្នា រាប់អានគ្នាសង្គ្រោះគ្នាទៅវិញទៅមកក្នុងឋានៈជាសមាជិកគ្រួសារតែមួយរហូតដល់អវសានៃជីវិត ។

ឯកឧត្តមសេនីយ៍ សូ សាតូ បានថ្លែងក្នុងពិធីនោះថា ជាងកន្លះសតវត្សរ៍មក ហើយដែលទ័ពអាកាសខ្មែរបានចាប់បដិសន្ធិហើយរីកដុះដាលក្លាយទៅជាទ័ពអាកាសមួយ ដែលមានហេដ្ឋានរចនាសម្ព័ន្ធយន្តហោះគ្រប់ប្រភេទ និងមានបុគ្គលិកបម្រើការដែលមានជំនាញ និងវិជ្ជាជីវៈខ្ពស់ ពោល គឺទ័ពអាកាសមួយដែលអាចការពារជាតិ បូរណភាពទឹកដី មាតុភូមិ និងប្រជាពលរដ្ឋដែលគួរឱ្យមានមោទនភាពជាទីបំផុត ។ ទ័ពអាកាសខ្មែរ គឺបានប្ដេជ្ញាចិត្តលះបង់ជីវិតក្នុងន័យបម្រើជាតិមាតុភូមិយ៉ាងប្ដូរផ្ដាច់ជាទីបំផុត ។

រីឯអ្នកអង្គម្ចាស់ Rathary Dimang Sisowath បានថ្លែងថា "កាលពីសម័យដែលយើងចាប់ផ្ដើមចូលខ្លួនបម្រើកងទ័ពអាកាសខ្មែរយើងមានមាឌធំ ខ្ពស់សង្ហារ នាំម៉ូដវ៉ែនតា Ray Ban និងនាឡិកា Omega កាលីហ្ស័រនីញ៉ាំនេះឯង ។ នេះជាលើកទី១ហើយដែលសមាជិកទ័ពអាកាសខ្មែរធ្វើពិធីជួបជុំគ្នាជាទ្រង់ទ្រាយធំ ដែលមិនធ្លាប់មានតាំងពី៣៥ ឆ្នាំកន្លងមកហើយ។ ក្នុងឱកាសនេះដែរ មានសមាជិកទ័ពអាកាសពីប្រទេសបារាំងមួយចំនួន ជាពិសេស លោកអតីតឧត្តមសេនីយ៍ អគ្គមេបញ្ជាការទ័ពអាកាសខ្មែរ សូ សាតូ ក៏បានអញ្ជើញមកចូលរួមជាកិត្តិយសក្នុងពិធីនេះដែរ ។ នេះប្រាកដជាការជួបជុំមួយប្រកបដោយមនោសញ្ចេតនារំភើបរីករាយរកអ្វីមកប្រៀបពុំបានឡើយ ។

មុខធំៗចូលទៅក្នុងប្រទេសកម្ពុជា យើងហោះហើរសម្ដែងឫទ្ធិក្នុងអាកាសលើបក្សាស្នាបដែក ឥឡូវនេះ សង្ហារតែខាងក្រៅទេ Ray Ban ក្លាយទៅជា Ray Ban បក្សាស្នាបដែកក្លាយទៅជាដំបងដែកសម្រាប់ទប់ខ្លួនទៅវិញ ។

ក្នុងរបបសាធារណៈរដ្ឋខ្មែរ កងទ័ពអាកាសខ្មែរមានចំនួនជាង9000នាក់ ជាមួយយន្តហោះគ្រប់ប្រភេទសរុប 248គ្រឿងសម្រាប់ការហោះហ៊ឺកហ៊ឺន ការទំនាក់ទំនង និងដឹកនាំកងប្រដេញប្រយុទ្ធយន្តហោះកងសង្កេតការណ៍ និងកងឧទ្ធម្ភាតចក្រ ។

នៅក្នុងសមរភូមិសង្គ្រាមនាអតីតកាលនោះ គេប៉ាន់ស្មានថា មានទាហានទ័ពអាកាសដែលបើកយន្តហោះប្រយុទ្ធចំនួនជាង300នាក់បានស្នាប់បាត់បង់ជីវិត ដើម្បីរក្សាការពារមាតុភូមិជាទីស្រឡាញ់របស់ពួកគេ។

អំពីដើមកំណើតនៃកងយោធពលអាកាសខ្មែរ រហូតមកដល់សម័យសង្គ្រាមលោកលើកទី2 ទៅហើយ ពុំមានកុលបុត្រខ្មែរណាម្នាក់បានបើកបរយន្តហោះទេ ។ ទើបតែក្នុងឆ្នាំ 1939 បានព្រះអង្គម្ចាស់ Sisowath Moni pong បាន ចេញពីសាលាអាកាសយានិកនៅ Provence ប្រទេសបារាំង និងព្រះអង្គម្ចាស់ Norodom Songdeth បានចូលរួមក្នុងបេសកកម្មទម្លាក់គ្រាប់បែកក្នុងសង្គ្រាមលោកលើកទី2រវាងប្រទេសបារាំង និងប្រទេសអ៊ីតាលី ។

ក្រោយសម័យឯករាជ្យបារាំងបានប្រគល់អំណាចកងទ័ពមកឱ្យខ្មែរកាន់កាប់ ទើបព្រះករុណា នរោត្តម សីហនុ តាមព្រះរាជក្រឹត្យមួយក្នុងឆ្នាំ 1954 បានបង្កើតកងយោធពលអាកាសខ្មែរ ហើយបានតែងតាំងលោក Ngo Hou ដែលជា វេជ្ជបណ្ឌិតក្នុងឋានន្តរសក្តិជាវរសេនីយ៍ទោ និងលោក Keu Pau An ដែលជាអធិការក្រសួងរុក្ខាប្រមាញ់ និងនេសាទ ក្នុងឋានន្តរសក្តិជាអនុសេនីយ៍ឯកឱ្យរៀបចំកងទ័ពអាកាសខ្មែរក្រោមការណែនាំរបស់បេសកកម្មយោធាបារាំងប្រចាំប្រទេសកម្ពុជា ។ កងទ័ពអាកាសខ្មែរជំនាន់ទី1 បានចាប់កំណើតនៅឆ្នាំ1954 និងជំនាន់ចុងក្រោយទី11បានចាប់កំណើតនៅឆ្នាំ1974 ។

ទ័ពអាកាសខ្មែរ
Khmer Air Force

•••ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ សមាជិកទ័ពអាកាសខ្មែរមួយចំនួនបានភៀសខ្លួនចេញពីប្រទេសនៅថ្ងៃចុងក្រោយនៃសង្គ្រាមក្តៅកាន់ប្រទេសសៀម រួចបន្តទៅកាន់ប្រទេសទីពា មានសហរដ្ឋអាមេរិក និងប្រទេសបារាំងជាដើម ភាគច្រើននៅសហរដ្ឋអាមេរិក ហើយភាគច្រើនទៅទៀត គឺត្រង់ភាគខាងត្បូងនៃរដ្ឋ

ការបដិសន្ធិ និងប្រវត្តិនៃអាកាសចរខេមរភូមិន្ទ

ព្រះអង្គម្ចាស់ ស៊ី សុវត្ថិមុនីពង្ស ជាអាកាសយានិកលើកទី១ នៃប្រវត្តិសាស្ត្រខ្មែរក្នុងឆ្នាំ១៩៣៩

ព្រះអង្គម្ចាស់ ស៊ី សុវត្ថិមុនីពង្ស ជាអាកាសយានិកនៅក្នុងទ័ពអាកាសបារាំងក្នុងសហព័ន្ធឥណ្ឌូចិនឆ្នាំ១៩៤០ ព្រះអង្គស្ថិតនៅក្នុងកងសង្កេតការទទួលបន្ទុក ឥណ្ឌូចិន មានកន្លែងដាក់ផងដែរ

ការចាប់ផ្ដើម

នៅមុន និងក្នុងរយៈពេលសង្គ្រាមលោកលើកទី២ ខេមរជនតិចណាស់ដែលមានវាសនាជាអ្នកហោះហើរនៅលើបក្សីស្នាបដែក។ ដោយសារជំនាន់នោះ ប្រទេសខ្មែរយើងស្ថិតនៅក្នុងសហព័ន្ធបារាំង អាកាសយានិកខ្មែរត្រូវហោះនៅក្នុងទ័ពអាកាសបារាំង ។

សៀវភៅទ័ពអាកាសខ្មែរមានបរិយាយពីប្រវត្តិនៃការកកើតទ័ពអាកាសចរខេមរភូមិន្ទក្នុងសម័យរាជានិយម រហូតមកដល់ទ័ពអាកាសខ្មែរក្នុងសម័យសាធារណរដ្ឋខ្មែរ។ សៀវភៅនេះ នៅមានរៀបរាប់ពីនាយទាហានជំនាន់ទី១រហូត ដល់ជំនាន់ទី១១ ហើយនិងរៀបរាប់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទាំងឡាយ ដែលទាក់ទងទៅនឹងទ័ពអាកាសខ្មែរផងដែរ ។

សូមរង់ចាំអានប្រវត្តិទ័ពអាកាសខ្មែរពីឆ្នាំ១៩៧៥ ដែលមានចេញផ្សាយក្នុងពេលឆាប់ៗនេះ ។

បញ្ជាការអាកាសចរខេមរភូមិន្ទ ហើយមានឋានន្តរស័ក្តិជាវរសេនីយ៍ទោ និង**លោក គើ ប៊ូអាន** ជាមេព្រៃក្លាយជាមេបញ្ជាការរង ហើយមានឋានន្តរស័ក្តិជាអនុសេនីយ៍ឯក។ បុគ្គលិកជាច្រើនរូបទៀតពីកងទ័ពថ្មើរជើងបានផ្ទេរឱ្យមកបំរើទ័ពអាកាស ហើយកាលនោះមានទីប្រឹក្សារបស់ទ័ពអាកាសបារាំង ដែលមានលោក វរសេនីយ៍ត្រី De Salabery ជាមេបញ្ជាការ។ ក្រោយមកទៀត ទីប្រឹក្សាទ័ពអាកាសបារាំងបានបើកវគ្គសិក្សាហ៊ឺកហ៊ឺនអាកាសយានិកខ្មែរ ដែលបង្ហាត់ដោយគ្រូបារាំងជាច្រើននាក់ ដូចជា André Bellouard ជាដើម ។

(សូមអាន André Bellouard note និងព័តិមានច្រើនទៀតនៅ

Website www.khmerairforce.com

អាថ៌កំបាំង និងសិល្បៈនៃជីវិត
SECRET AND ART OF LIVING

(តមកពីលេខមុន)

រៀបរៀងដោយ
លោក ម៉ៅ ច័ន្ទសំណុំ

•••ឥឡូវនេះ យើងចូលទៅក្នុងបន្តិចពិនិត្យពិភពនៃចិត្តមនុស្សម្តងមើល ។ តើខ្ញុំជាចិត្តដែលកំពុងតែគិតកំពុងតែមានចិត្តរដើបរំជួលឬ? ពីមុនខ្ញុំតែងគិតថា ពិភពចិត្ត អារម្មណ៍ ការគិត កំហឹង ការនឹកឃើញ ។ល។ ជាតួរបស់ខ្ញុំ ជាសកម្មភាពរបស់ខ្ញុំ។ ឆ្លងតាមការពិចារណាលើកុងស្សនិសពេលដឹងខ្លួន Waking state និងកុងស្សនិសពេលយប់ សប្តិ Dreaming state ខ្ញុំមើលឃើញថា ពិភពផ្លូវចិត្តនេះពុំមែនខ្ញុំទេ។ ការគិត អារម្មណ៍ ប្រតិកម្ម មនោសញ្ចេតនា និន្នាការ ។ល។ ដែលកំពុងតែប្រព្រឹត្តទៅក្នុងចិត្តខ្ញុំនេះ **គឺជាការឆ្លើយឆ្លង ឬជះត្រឡប់ទៅមកជាស្ថិយប្រវត្តិរវាងប្រអប់ម៉ែម៉ី និងពិភពខាងក្រៅខ្លួនប៉ុណ្ណោះ ។** ឧទាហរណ៍ : ខ្ញុំកំពុងអង្គុយ ស្រាប់តែឮសូរសម្លេងចម្លែកពីក្រៅផ្ទះមក សម្លេងពីក្នុងខ្លួនប្រាប់ថា មានហេតុអ្វីកើតឡើងហើយ ចូរចេញទៅមើល ! ខ្ញុំស្ទុះចេញទៅភ្លាម ឃើញឡានប៉ះគ្នា ។ សម្លេងមួយទៀតពីក្នុងមកថា ឡានរបស់នរណា ជារបស់កូនអញទេឬ? ។ល ។និង ។ល ។ បើអ្នកទៅមើលឡាន ការរកសោរដើរឆ្ពោះទៅឡាន ចូលអង្គុយ មូលសោរឡាន បើកភ្លើកឆ្វេងស្តាំ ដៃកាច់ចង្កូត ។ល ។ ហេតុការណ៍ និងសកម្មភាពទាំងអស់នេះ កើតឡើងជាស្ថិយប្រវត្តិ ជាទម្លាប់បញ្ជាពីក្នុងមក ។ ដូចខ្ញុំដាវបជូនខាងលើស្រាប់ពិភពផ្លូវចិត្តនេះ (ការគិត កំហឹង អារម្មណ៍) មានចរិត "ដែលមានចំនាក់ចំនង" វារណបទៅនឹងកុងស្សនិសបរិសុទ្ធនេះ វាពុំមានឯករាជ្យឈរម្នាក់ឯងបានឡើយ។ ដូច្នេះ ពិភពផ្លូវចិត្តនេះ ពុំមែនជាខ្ញុំទេ ពុំមែនរបស់ខ្ញុំទេ។ ចំណុចនេះហើយ ដែលព្រះពុទ្ធសាសនាលើកនូវទ្រឹស្តីអនត្តា NO SELF (ដំណើរប្រព្រឹត្តទៅដោយឯកឯងនៃខន្ធ៥មានរូបកាយ វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ដែលមានចរិកជាភាពចំនាក់ចំនង) ។

បើកខ្ញុំពុំមែនជារូបកាយនេះ ជាចិត្តនេះ តើខ្ញុំជានរណា? តើធម្មជាតិពិតរបស់ខ្ញុំជានរណា? ឥឡូវនេះយើងចូលជ្រៅមួយជាន់ទៀត ។

ដូចខ្ញុំបានរៀបរាប់ក្នុងការប្រៀបធៀប ទឹក ដី និងវត្ថុធ្វើអំពីដី ពន្លឺក្នុងម៉ាស៊ីនបញ្ចាំងកុន យើងបានឃើញថា កុងស្សនិសបរិសុទ្ធ ជាជីវិត life ជាសតិដឹង Awareness ជាអ្នកមើលពីក្នុងមក The observer From the inside out ជាមូលដ្ឋានគ្រឹះ ជាដើមចមនៃការកេ Creation អ្វីៗទាំងអស់ក្នុងខ្លួនមនុស្សនេះ : ចលនាសរីរាង្គមានបេះដូង សួត ថ្លើម ប្រមាត់ ម៉ែម៉ែរ លំហូរគំនិតប្រតិកម្ម ការរំជួលផ្លូវចិត្ត វេទនា អារម្មណ៍ ។ល ។ ដំណើរប្រព្រឹត្តទៅនៃរូបកាយ និងពិភពចិត្តមនុស្សកើតចេញមកពីកុងស្សនិសបរិសុទ្ធ ហើយរលាយបាត់ក្នុងទីនោះវិញ សារចុះសារឡើង ។ ដូច្នេះ កុងស្សនិសបរិសុទ្ធជាធម្មជាតិពិតរបស់ខ្ញុំ ។ The puer consciousness is my true nature .

ការយល់ដោយប្រាជ្ញាថា កុងស្សនិសបរិសុទ្ធជាធម្មជាតិពិតរបស់ខ្ញុំ "ខ្ញុំពុំមែនជារូបកាយនេះទេ" ខ្ញុំពុំមែនជាចិត្តនេះទេ"ជាជំហានមួយដ៏ធំឆ្ពោះទៅរកការរួមរំដោះ និងសេរីភាព។ គួរយើងយល់ដឹងមួយកំរិតទៀតក្នុងវិស័យប្រតិបត្តិផ្ទាល់តាមពិសោធផ្ទាល់ ។ មនុស្សមានលទ្ធភាពនឹងដាក់សតិ ឬតំរង់សតិ ឬប្រមូលផ្តុំសតិ Put the attention or focus the attention or concentrate the attention ទៅក្រៅខ្លួន ទៅលើរូបកាយ ទៅក្នុងចិត្ត ឬពិសេសទៅក្នុងកុងស្សនិសបរិសុទ្ធ។ យើងអាចដាក់សតិទៅលើស្បែវភៅ ដើម្បីអានស្បែវភៅ (ខាងក្រៅ) ។ ពេលណាយើងដើរទង្គិចប៉ះក្បាល ឬជើង សតិយើងនឹងបាញ់រកក្បាល ឬជើង(លើរូបកាយ) ។ ថ្នឹងថ្នែងស្រាវជ្រាវរកហេតុផល(លើផ្ទៃចិត្ត) ។ ពេលយើងខឹងមួរម៉ៅ សតិយើងបានស្រូបទាំងស្រុងទៅក្នុងកំហឹងមួរម៉ៅ ហើយលង់សតិនៅទីនោះ "បាត់សតិ" (លើការរំជើបរំជួលចិត្ត emotion) ។

អ្វីដែលខ្ញុំរៀបរាប់មកនេះ អ្នកពិតជាពិសោធដូចខ្ញុំដែរ។ ប៉ុន្តែការតម្រង់សតិទៅតំបន់កុងស្សនិសបរិសុទ្ធ អ្នកពុំធ្លាប់ ហើយពុំដឹងជាធ្វើដូចម្តេចផង។ ប្រហែលយូរៗម្តង សតិអ្នកធ្លាក់ដោយចៃដន្យ ឬចូលជ្រៅទៅក្នុង ហើយសំឡឹងមើលពីក្នុងមក As observer or to be aware ទទួលដឹងថា មានអ្វីកំពុងកើតមាននៅក្រៅខ្លួន លើរូបកាយ ក្នុងចិត្ត អារម្មណ៍ (ដឹងដោយពុំមានការជ្រៀតជ្រែកពីម៉ែម៉ី ឬពីការគិតដោយខូរក្បាល -Knowing without interfering from unconscious mind or menory) ពិសោធរបៀបនេះ គឺលោកអ្នកបានទៅដល់តំបន់កុងស្សនិសបរិសុទ្ធហើយ ។ ប៉ុន្តែលោកអ្នកពុំអាចវែកញែកឱ្យច្បាស់ដូចអ្នកសមាធិបានឡើយ ។ សូមកុំព្រួយ សូមបន្តអានអ្នកនឹងដឹងច្បាស់ពុំខានឡើយ ។

ពេលនេះអ្នកគ្រាន់តែដឹងថា មនុស្សមានសមត្ថភាពអាចប្រមូលសតិទៅតំបន់កុងស្សនិសបរិសុទ្ធបានពិតជាបាន ហើយអាចពិតជាអាច ។ នេះជាសមត្ថភាព ដែលមនុស្សគ្រប់រូបមានសិទ្ធិនឹងទទួលពីធម្មជាតិ យើងត្រូវទាមទារសិទ្ធិពីកំណើតនេះឱ្យបាន ។ ចាំបាច់អ្នកមានកិច្ចការត្រូវធ្វើ ត្រូវហាត់ ព្រោះសមត្ថភាពនេះ ពុំកើតឡើងឯកឯងឡើយ ។ ពេលណាអ្នកចេះរបៀបហើយចេះតិកនិចហើយ ចេះម៉ែតូដហើយ អ្នកនឹងមានបន្ទប់ពីរក្នុងខ្លួន បន្ទប់មួយសម្រាប់ពិសោធពិភពខាងក្រៅ(តិតទទួលអារម្មណ៍) ហើយបន្ទប់មួយទៀត សម្រាប់សម្រាក ក្រេមជញ្ជក់សើរភាព សុខសាន្ត សប្បាយរីករាយក្នុងអារម្មណ៍ សន្តិភាពក្នុងចិត្តប្រាជ្ញាសាកល (ដែលជាសិទ្ធិពីកំណើត Birth Right) ។ល ។ *(តទៅលេខក្រោយ)*

New World Travel II
ញូវលត្រាវែលធ្ង
Specialized in Selling Flight Tickets
For National and International
ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉ែ កាថេ ។ល ។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបានទិញសំបុត្រជិះនាវាសមុទ្រ សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។
Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

ANGKOR AUTO SERVICE, INC.
ហាងជួសជុលរថយន្ត"អង្គរ"
4835 N. 16th Street. Tel : (215) 455-7810
Philadelphia, Pa 19141 Ricky : (215) 485-1425
Specializing in Body Kit and Custom Paint
ជំនាញខាងជួសជុលតួរថយន្ត
និងបាញ់ថ្នាំជាក់ក្បាច់តាមបំណងភ្ញៀវ
RICKY
Hand Ph.: Ricky 215-485-1425
មុនពេលជួសជុល
ក្រោយពេលជួសជុល
មានបទពិសោធន៍២០ ឆ្នាំ
ជាជាងរថយន្តមានសញ្ញាប័ត្រ
វាយតម្លៃការងារដោយឥតយកថ្លៃ
ហើយយើងជួយសន្សំប្រាក់តម្លៃ
បន្ថយរបស់អ៊ីនស៊ួរិន បានផង
យើងផ្តល់សេវាគ្រប់យ៉ាង :
-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C
បើកពីម៉ោង ៩ ព្រឹក
ដល់ម៉ោង៥ល្ងាច ពីថ្ងៃ
ច័ន្ទ ដល់ ថ្ងៃ សៅរ៍
ចុះតម្លៃជូន 10 % បើបង្ហាញប័ណ្ណពាណិជ្ជកម្មនេះ

ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

ប្រែសម្រួលដោយ : ពិន សំខុន (តពីលេខមុន)

-គេកត់សម្គាល់ថា មានប្រទេសកម្ពុជាដល់ទៅពីរ គឺ១ នៅក្នុងស្រុក រស់នៅដោយសារសហគមន៍អន្តរជាតិ ហើយទី២ នៅជំរំទល់ដែន បានទទួលការចាប់អារម្មណ៍យ៉ាងក្រាសក្រែល។

ឆ្នាំ ១៩៨១

•៨ កុម្ភៈ : សម្តេច សីហនុ ប្រកាសថា ព្រះអង្គត្រៀមខ្លួនដើម្បីដឹកនាំចលនារួបរួមជាតិមួយដែលប្រមូលផ្តុំដោយអ្នកប្រឆាំងរបបភ្នំពេញ ។

•២៦ មីនា : បង្កើតហ៊ុនសុិនប៊ិច FUNCINPEC នៅក្រុងប៉ារីស ប្រទេសបារាំង សម្តេច សីហនុ ជាព្រះប្រធាន។

•១ ឧសភា : បោះឆ្នោតសភាជាតិនៅភ្នំពេញ -អាសនៈមាន១១៧-បេក្ខជនមាន១៤៨ ទាំងអស់សុទ្ធតែទទួលការឃល់ព្រមពីចលនារំដោះ FUNSK ។

•២៦-២៩ ឧសភា : មហាសន្និបាទលើកទី៤ របស់បក្សប្រជាជន - ប៉ែន សុវណ្ណ ដែលជាអ្នកបង្ហាញសេចក្តីរាយការណ៍ជាប្រវត្តិសាស្ត្របានជាប់ឆ្នោតសារជាថ្មី ជាអគ្គលេខាបក្ស - សន្និបាតតែងតាំងគណៈកម្មាធិការកណ្តាល ២១ នាក់ សមាជិកការិយាល័យនយោបាយ ៨ នាក់ និងសមាជិកការិយាល័យរដ្ឋបាល ៧នាក់ ។

•២៨ មិថុនា : ប្រជុំពេញអង្គសភាជាតិ លើកទី១ ជា ស៊ីម ជាប្រធាន

•២៧ មិថុនា : សភាជាតិបានអនុម័តលើអត្ថបទរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ពេលនោះបានតែងតាំងប្រឹក្សារដ្ឋម្នាក់ គឺ ហេង សំរិន និងប្រធានប្រឹក្សាគណៈរដ្ឋមន្ត្រី គឺ ប៉ែន សុវណ្ណ

•២ កក្កដា : គណៈរដ្ឋមន្ត្រីរដ្ឋាភិបាល ប៉ែន សុវណ្ណ

២-រដ្ឋាភិបាល ប៉ែន សុវណ្ណ (២-៧-១៩៨១-៤-១២-១៩៨១) :

-នាយករដ្ឋមន្ត្រី : ប៉ែន សុវណ្ណ
-ប្រធានខុទ្ទកាល័យនៃក្រុមប្រឹក្សារដ្ឋមន្ត្រី : អ៊ុង ផន
-ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការពារជាតិ : ចាន់ ស៊ី
-ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីផែនការ : ជា សុទ្ធ
-ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការបរទេស : ហ៊ុន សែន
-រដ្ឋមន្ត្រីមហាផ្ទៃ : ខាង សារិន
-រដ្ឋមន្ត្រីកសិកម្ម : គង់ សំអុល
-រដ្ឋមន្ត្រីឧស្សាហកម្ម : កែវ ចិន្តា
-រដ្ឋមន្ត្រីគមនាគមន៍ និងប្រៃសណីយ៍ : ឃុន លី
-រដ្ឋមន្ត្រីពាណិជ្ជកម្ម : តាំង សារីម
-រដ្ឋមន្ត្រីហិរញ្ញវត្ថុ : ចាន់ ភិន
-រដ្ឋមន្ត្រីកិច្ចការរដ្ឋ : ស៊ីម កា
-រដ្ឋមន្ត្រីអប់រំ : ប៉ែន ណាវុធ
-រដ្ឋមន្ត្រីសុខាភិបាល : យិត គីមសេង
-រដ្ឋមន្ត្រីព័ត៌មាន និងវប្បធម៌ : ឆេង ផុន
-រដ្ឋមន្ត្រីយុត្តិធម៌ : អ៊ុក ប៊ុនឈឿន
-នាយកធនាគារជាតិ : ចា វ៉ឿង

(តទៅលេខក្រោយ)

ផ្ទះបីកន្លែងដែលធើប
ជូសជុលហើយថ្មីស្រឡាង

-នៅទីប្រជុំជន ដែលសម្បូរណ៍ដោយអ្នកត្រូវការផ្ទះឈ្នួល
-តម្លៃថោកជាងតម្លៃទីផ្សារ តម្លៃ ៥.៥ ម៉ឺន ឬអ្នកឱ្យថ្លៃខ្ពស់ជាងគេ
-អាចចូលនៅបានភ្លាម បើជួលបានតម្លៃល្អ
ផ្ទះនីមួយៗមានបីបន្ទប់ដេក-ជាន់កណ្តាលមានផ្ទះបាយ បន្ទប់ទទួលភ្ញៀវ
ធំទូលាយជាន់ក្រោមដីមានទីកក្តៅ និងម៉ាស៊ីនផ្តល់កំដៅសំរាប់ខែរងា

1-2137 MARTSTON STREET | 2-2062 S. CECIL STREET | 3-1716S. RINGGOLD STREET

សូមទូរស័ព្ទរក (215) 481-0789 ដើម្បីមើលផ្ទះ

ពុទ្ធប្បវត្តិអមដោយរូបភាព

A Pictorrial Biography of Saky amuni Buddha

❖ រូបភាព និងរឿងដើមជាភាសាថៃ ដោយ គុណាប៉ាយុតា
❖ បកប្រែជាភាសាអង់គ្លេស ដោយ ហ្សឺត .អេ.លី
❖ ផាត់ពណ៌ដោយ យ៉ាន់ ហ្វាលី
❖ បកប្រែជាភាសាខ្មែរដោយភិក្ខុ គង់ អាំ

❖ Original Illuatration and Naration in Thai by Gunapayuta.
❖ Translation into English by A Lu.
❖ Coloring by Yann Fang Lee
❖ Translation into Khmer by Bhikkhu Kong Am.

៨៣- អស់ពេលពេញមួយថ្ងៃ ព្រះអង្គទ្រង់គង់យ៉ាងស្ងៀមស្ងាត់ និងសប្បាយរីករាយក្នុងព្រៃឧទ្យានព្រះទ័យទ្រង់ដក់ជាប់តែនឹងការគិតសាងបព្វជ្ជាតែប៉ុណ្ណោះ ។ ពេលនោះស្រាប់តែមានគេទៅក្រាបបង្គំទូលថា ព្រះរាជទេពីរបស់ព្រះអង្គប្រសូត្របានបុត្រមួយព្រះអង្គគួរជាទីស្រឡាញ់ ។ ទ្រង់មិនសំដែងសេចក្តីត្រេកអរចំពោះដំណឹងនេះឡើង ព្រះអង្គទ្រង់ត្រឡប់ជាមានព្រះកង្វល់ខ្វល់ខ្វាយព្រះទ័យទៅវិញ ហើយទ្រង់មានព្រះបន្ទូលយ៉ាងសោះកក្រោះថា ចំណងនេះបានចងអញហើយតើ! ចំណងនេះបានចងអញហើយតើ! បានជាទ្រង់មានព្រះបន្ទូលដូចនេះ ដោយសារពេលនេះបុត្រទើបប្រសូត្រថ្មីមានព្រះនាមថា **រាហុល** នោះដែលមានន័យថា **ចំណង** ឬ **អន្ទាក់** ។

៨៤- ចាប់តាំងពីថ្ងៃដែលរាហុលកុមារប្រសូតមកជនទាំងឡាយដែលនៅជាប់ជាមួយព្រះសិទ្ធត្ថ បានសង្កេតឃើញយ៉ាងច្បាស់ថា ព្រះរាជឱរសទ្រង់មានការប្រែប្រួលយ៉ាងច្រើន។ ព្រះអង្គទ្រង់មានព្រះអាការៈស្រពាប់ស្រពោន និងសញ្ជប់សញ្ជឹងខ្លាំងជាងពេលមុនៗទាំងអស់ ។ ចំណែកព្រះមហាក្សត្រសុទ្ធោទនៈវិញ ទ្រង់ព្រះវិត្តក្តៈខ្វល់ខ្វាយក្រៃមក្រំបារម្ភព្រួយក្រៃលែងចំពោះអាការៈខុសពីធម្មតារបស់ព្រះរាជបុត្រព្រះអង្គ ដូច្នេះព្រះរាជាទ្រង់ខំព្យាយាមទាក់ទាញដ៏ខ្លាំងក្លាជាចុងក្រោយ ដើម្បីដាស់អារម្មណ៍ព្រះរាជបុត្រឱ្យភ្ញាក់ទាក់ជាប់ចិត្តស្រើបស្រាលឡើងវិញ ដោយទ្រង់ជ្រើសរើសយកតែកុមារីស្រីរបាំដែលមានទេពកោសល្យប៉ិនប្រសប់ និងមានរូបឆោមស្រស់ស្អាតបំផុតក្នុងព្រះនគរឱ្យចូលមករាំច្រៀងកំដរព្រះរាជបុត្រ ។ ព្រះរាជាទ្រង់ត្រាស់ឱ្យពួកស្រីរបាំទាំងនោះស្ថិតនៅជាប់ជានិច្ចទាំងយប់ទាំងថ្ងៃក្នុងដំណាក់ព្រះរាជឱរស និងទ្រង់ត្រាស់បង្គាប់ឱ្យច្រៀងតែចម្រៀងពិរោះៗ និងរាំតាមចង្វាក់ទាក់ទាញអារម្មណ៍ឱ្យបានសប្បាយ ធ្វើដូច្នោះព្រះអង្គទ្រង់សង្ឃឹមថា វានឹងដាស់ពញាក់អារម្មណ៍ព្រះរាជបុត្រឱ្យត្រេកត្រអាលសប្បាយភ្លើតភ្លើន និងពេញព្រះទ័យចំពោះវត្ថុផ្សេងៗនាលោកិយនេះ ។

(តទៅលេខក្រោយ)

83- During that whole day, the prince sat quietly but happily in the garden, his mind captured by the idea of becoming a Sramana. Just then someone told the prince that his wife had given birth to a lovely boy. but instead of expressing his joy, the prince was a bit flusterd, and he said absentmindedly: "This ring has hemmed me in!" It was because the prince spoke in this manner just at this time that the newborn baby was named Rahula, which means a ring or a circle.

84- Since the day of Rahula´s birth, those who lived with Prince Siddhartha all chearly observed that the prince had changed entirely. He was more solemn than before and more contemplative. King Suddhodana was very worried indeed, about his son´s condition; and so he tried with his last effort to re-awaken his interest by searching the whole country for the interligent and beautifull dancing girls. permanetly in the prince´s palace, ordering them to sing beautifull songs and to perform pleasing dances, which, he hoped, would arouse the prince´s pleasure and interest in the thing of this world. *(Continued Issue After)*



Leema's 168 Market
5010 Old York Rd, Philadelphia, PA 19141-2707
Contact Phone: (215) 455-1003
ផ្សារខ្មែរ លីម៉ា 168



តមកទំព័រទី០៣ ខុច សម្លាប់មនុស្សជាង១ម៉ឺននាក់...

សម្រាប់សាលាក្តីខ្មែរក្រហមកាត់ទោសខ្មែរក្រហមខ្ញុំគិតថា វាអយុត្តិធម៌នៅតែមាន ពីព្រោះកាត់តែមនុស្ស 4-5 នាក់ហ្នឹង ។ អីចឹងខ្ញុំគិតថា វាត្រូវតែមានការពាក់ព័ន្ធផ្សេង១ទៀត សម័យ ប៉ុល ពត ពេលនោះខ្ញុំនៅតូច១ដែរ ដឹងពីការជាប់ពាក់ព័ន្ធរវាងប្រទេសជិតខាងដូចជាជាមួយយួន ជាមួយចិន មានជាប់ជំពាក់វាកិនគ្នានៅក្នុងសម័យខ្មែរក្រហមហ្នឹង ។ ប៉ុន្តែមិនធ្វើការចោទប្រកាន់អ្នកដែលនៅខាងក្រៅ ហើយអ្នកដែលនៅខាងក្នុងដែលជាតស្សរ-ជនមួយចំនួនកំពុងតែដឹកនាំរដ្ឋាភិបាលថ្ងៃមើលទៅក៏មានជាប់ពាក់ព័ន្ធទៅនឹងបាតដៃប្រឡាក់ឈាមផងដែរ ។ ប៉ុន្តែទុកឱ្យមានសេរីភាព ហើយកំពុងតែធ្វើការដឹកនាំបន្តបន្ទាប់ទៀត ។ នេះវាអយុត្តិធម៌មិនមានភាពស្មើគ្នាចំពោះការដែលចោទប្រកានិវិសាលភាពនៃច្បាប់សម្រាប់កាត់ទោសខ្មែរក្រហម ។ យើងសោកស្តាយតុលាការនេះច្បាប់បានសរសេរចងថា ក្នុងចំណោមសហចៅក្រមហ្នឹង បើមានអ្នកណាមួយជំទាស់មិនអាចយកធ្វើការចោទប្រកាន់បាន គឺវាទាក់នៅត្រង់ហ្នឹង ឃើញចៅក្រមអន្តរជាតិត្រោងនឹងចោទប្រកាន់មនុស្ស4-5នាក់ទៀត ប៉ុន្តែខាងភាគីខ្មែរយើងមិនឯកភាពត្រង់នេះយើងមើលឃើញថា វាមិនយុត្តិធម៌ ។

ហើយចំណែកលោក យឹម សុវណ្ណ មន្ត្រីអ្នកនាំពាក្យមកពីគណបក្ស សម រង្ស៊ី មានការគាំទ្រដូចម្តេចដែរ ?

យឹម សុវណ្ណ : នេះជារឿងធម្មតាជាការសម្រេចរបស់តុលាការ នេះយើងមិនធ្វើអត្ថាធិប្បាយអ្វីទេ។ ទី2 អ្នកនយោបាយទាំងអស់ត្រូវសហការជាមួយតុលាការខ្មែរក្រហមហ្នឹង ពីព្រោះតុលាការនេះជាតុលាការដែលចៅក្រមព្រះរាជអាជ្ញាអន្តរជាតិចូលរួមបើសិនជាមានការឆ្លើយបំភ្លឺបន្ថែមដោយទាមទារឱ្យមានការសហការពីអ្នកនយោបាយណាគួរណាស់ឱ្យមានការសហការជាមួយតុលាការហ្នឹង ធ្វើយ៉ាងណាកាត់សេចក្តីឱ្យមានភាពយុត្តិធម៌ ហើយនឹងឱ្យបានរលូនទៅមុខ ។ ហើយគ្រាន់តែថា ប្រជាពលរដ្ឋមួយចំនួនមានការខកចិត្តដែរ ពីព្រោះថា មានតែខ្មែរក្រហម4-5នាក់ហ្នឹង ទេទៅសម្លាប់មនុស្សរាប់លាននាក់នោះទេ គឺមានខ្មែរក្រហមដទៃទៀតគួរណាស់ត្រូវបានយកមកកាត់ទោស ក៏ប៉ុន្តែកំពុងតែរស់នៅដោយមានសេរីភាព មានការការពារពីអ្នកនយោបាយថែមទៀត។

សម្រាប់លោក វណ្ណាត ដែលនៅរស់រានមានជីវិតពីគុកទួលស្វែងង៉កម្រ និងស្ថិតក្រោមការគ្រប់គ្រងរបស់ខុច លោកយល់ឃើញយ៉ាងដូចម្តេចដែ ?

វណ្ណាត : ព្រឹកមិញនេះខ្ញុំបានចូលរួមស្តាប់នៅក្នុងការកាត់ទោស ខុច ខ្ញុំស្តាប់ការប្រកាសជាផ្លូវការរបស់ប្រធានចៅក្រមលោករៀបរាប់អំពីតួនាទីអំពីការងារដែល ខុច គាត់ប្រព្រឹត្តិកន្លងមកសម្រាលទោស5ឆ្នាំចំពោះខ្ញុំ ខ្ញុំឯកភាពទទួលសេចក្តីសម្រេចរបស់តុលាការពីព្រោះ ថាការប្រឹងប្រែងរបស់តុលាការក៏ចំណាយពេលយូរដែរហេតុដូច្នេះខ្ញុំសម្លឹងមើលទៅប៉ុណ្ណឹងវាយុត្តិធម៌ ។

ចំណែកឯនិស្សិតឆ្នាំទី2នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកសារព័ត៌មានលោក ឆេង សំបូរ លោកយល់ឃើញយ៉ាងដូចម្តេចដែរ ?

ឆេង សំបូរ : បាទ ! តាមទស្សនៈរបស់ខ្ញុំ ខ្ញុំគិតថា តុលាការកាត់ក្តីដាក់ទោសប៉ុណ្ណឹងវាមិនសាកសម ដែលតុលាការគាត់កាត់35ឆ្នាំ ខ្ញុំក៏ដូចជាអ្នកដទៃខ្ញុំមានអារម្មណ៍មិនពេញចិត្តដែរ មិនគួរណាគាត់ធ្វើគាត់សម្លាប់មនុស្សរាប់លាននាក់ ទោះបីជាគាត់ធ្វើតាមគេបញ្ជាឬយ៉ាងណាក៏ដោយមនុស្សច្រើនបានស្លាប់ដោយសារគាត់។

កញ្ញា សេង ធារី ដើមបណ្តឹងជនរងគ្រោះរដ្ឋប្បវេណីនៃសំណុំរឿង001បានថ្លែងថា :

សេង ធារី : ចាស ! យើងឃើញថា សាលក្រមប្រកាសកាលពីព្រឹកមិញនេះជាសាលក្រមដែលយើងមិនអាចទទួលយកបាន

ក្នុងនាមជាជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម ពីព្រោះជនរងគ្រោះស្ថិតនៅក្រោមកណ្តាប់ដៃរបស់ខុច នៅគុកទួលស្វែង ។ អ្វីដែលបានកើតឡើងកាលពីព្រឹកមិញយើងមានភាពឆ្ងល់ យើងមានការព្រួយបារម្ភពីការជ្រើរតជ្រែកផ្នែកនយោបាយដែលអាចជះឥទ្ធិពលទៅលើសំណុំរឿង 002 ។ អីចឹងសាលក្រមកាលពីព្រឹកមិញសាលក្រមមួយដែលធ្វើឱ្យយើងមានការរន្ធត់មានភាពឆ្ងល់ មានភាពល្វីងជូចត់នៅក្នុងការជឿថា អ្វីដែលគាត់បានធ្វើគាត់ប្រព្រឹត្តិតុលាការយុត្តិធម៌បានផ្តល់ឱ្យគាត់ត្រឹមតែ19ឆ្នាំ មានន័យថា ជីវិតមួយគាត់បានបង់តែ 11ម៉ោងក្នុងការទទួលធ្វើទារុណកម្មទៅនឹងភាពយោរយៅទៅលើភាពបាត់បង់ជីវិតមួយ ហើយយើងគុណនិង 14,000នាក់ យើងគិតមើល ។ អីចឹងអ្វីដែលកើតឡើង ជារឿងមួយហើយបារម្ភថា មានការជ្រើរតជ្រែកពីអ្នកនយោបាយធ្វើឱ្យយើងមានការអស់សង្ឃឹមទៅនឹងករណីសំណុំរឿង 002 ។

ចំពោះព្រះតេជគុណ ផាន់ សៅរ៉ា ដែលគង់នៅវត្តឧណ្ណាឡោម តើព្រះអង្គមានសង្ឃដីកាយ៉ាងដូចម្តេចដែរ?

ផាន់ សៅរ៉ា : ចំពោះអាត្មាផ្ទាល់35ឆ្នាំសមនឹងអាយុគាត់ ពីព្រោះឥឡូវអាយុគាត់ប្រហែលជា70ឆ្នាំ អីចឹងគាត់35ឆ្នាំលួមត្រឹមអាយុគាត់ប៉ុណ្ណឹង ហើយនិយាយឱ្យចំទៅប៉ុណ្ណឹង គឺដូចមួយជីវិតរបស់គាត់ទៅហើយ ។

ទោះជាយ៉ាងណាក៏ដោយសហព្រះរាជ អាជ្ញាជាតិនិងអន្តរជាតិបានថ្លែងនៅក្នុងសន្និសីទកាសែតបន្ទាប់ពីប្រកាសសាលក្រមផ្តន្ទាទោសនៅថ្ងៃនេះថា ពួកគេនៅមិនទាន់ច្បាស់ថា ត្រូវប្តឹងទៅឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនេះឬយ៉ាងណានោះទេ ។ ការប្តឹងឧទ្ធរណ៍នេះមាន30ថ្ងៃគិតចាប់ពីថ្ងៃនេះតទៅ ។ លោក កាំងហ្គិចអ៊ាវ ហៅ ខុច ត្រូវបានបញ្ជូនមកមន្ទីរឃុំឃាំងអង្គសវនាការនៃអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី30 ខែកក្កដា ឆ្នាំ2007 ។ សវនាការកាត់ទោស ខុច បានចាប់ផ្តើមនៅថ្ងៃទី30 ខែមីនា និងបានបញ្ចប់នៅថ្ងៃទី27 វិច្ឆិកា 2009 ក្នុងអំឡុងពេលសវនាការ ចំនួន77ថ្ងៃ ៕

From :Philadelphia

សួស្តីឆ្នាំថ្មី
ហាងខ្ញុំរជួសជុលរថយន្ត
បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ
Rathe`s Auto Service

State and Emission
Inspection General
Repairs and Maintenance
MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY
-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានជួរប្រេង ជួរប្រាំង ជួរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយ
ឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨
ទៅ : -ជួរប្រេងកែវត ៥ ក្លាត $22. - INSPECTIONS រថយន្តឆ្នាំ
96 up $49.99+ តាក់-មានជូនប័ណ្ណពិសេស សំរាប់ជួរប្រេង ចុះថ្លៃ
ពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេង១ទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយឫត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER
ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ សូមអគុណ !
5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

Yes you can!
... get free or low-cost health insurance for your children.
•Did you lose your health insurance when you lost your job?
•Do your children have no health insurance?
•Do you wonder how you'll afford your kids' next doctor visit?
AmeriChoice
A UnitedHealth Group Company
(215) 360-9841
Leap Thach
Your children deserve to be healthy.
AmeriChoice can help.


ហោរាសាស្ត្រ

ជោគជតារាសីលោកអ្នក ថ្ងៃទី១៣-២៦ សីហា ២០១០

ឆ្នាំជូត : (ពស្យធេព្ពាឃ្លួស ធាតុទឹក)

រាសីលោកអ្នកញើវខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ លោកអ្នកមានអារម្មណ៍ក្តីថ្នាំតំនិតច្រាជ្រាឈ្លាសវៃ ទោះបានប្រកបកិច្ចការងារអ្វី។ក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងច្រាថ្នាទាំងអស់ តែចូរកុំមានចិត្តលោភលន់ឲ្យសោះ ព្រោះការលោភលន់នាំមកនូវក្តីវិនាសអន្តរាយ ។ ចំពោះគូស្នេហ៍មានភាពលួកលើនយល់ចិត្តគ្នាល្អណាស់ ។

ឆ្នាំឆ្លូវ : (ពស្យមនុស្សឃ្លួស ធាតុដី)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបឧទិដ្ឋរឿងរ៉ាវកំសួសច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារអ្វី ក៏ដោយ ចូររៀបចំគម្រោងផែនការជាមុនទើបពុំមានការខ្ជោះធ្លោយ ។ ក្រៅពីនោះបើ មានរឿងឈ្លោះវិវាទកើតញើវ ចូរចេះអត់ធ្មត់ និងរម្ងាប់ចិត្តឲ្យបានត្រជាក់ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះច្រើនពាក់មុខឲយក្យដាក់គ្នា ។

ឆ្នាំខាល : (ពស្យយក្សឃ្លួស ធាតុឈើ)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះអ្វី ។ច្រើនមានការប្រែប្រួលពុំទៀងទាត់ញើយ ដូច្នេះបើលោកអ្នកមានលក់ដីធ្លីផ្ទះសម្បែង ឬវត្ថុមានតម្លៃផ្សេង។ ចូរធ្វើលិខិតស្នាមជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខា ឬផ្តិតស្នាមមេដៃឲ្យបានត្រឹមត្រូវទើបទៅថ្ងៃមុខពុំមានបញ្ហាចោទញើវ ។ គូស្នេហ៍មានភាពស្និទ្ធស្នាលដូចប្រក្រតី ។

ឆ្នាំថោះ : (ពស្យមនុស្សឃ្លួស ធាតុឈើ)

រាសីលោកអ្នកញើវខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ គឺរមែងតែបានទទួលផលសម្រេចសមតាមបំណងច្រាថ្នាទាំងអស់ ។ ក្នុងរយៈពេលនេះ បុរសត្រូវប្រយ័ត្នចំពោះមនុស្សស្រីដែលមានសម្តីដែមអាចរលាយទ្រព្យធាប់ ។ ចំពោះគូស្នេហ៍ប្រកបតែសេចក្តីសុខក្សេមក្សាន្ត ។

ឆ្នាំរោង : (ពស្យធេព្ពាឃ្លួស ធាតុមាស)

រាសីលោកអ្នកល្អមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះថ្វីត្បិតតែការងាររកស៊ីអាចរើប ។បន្តិចញើវក្តី តែអ្វីដែលលោកអ្នកគួរប្រយ័ត្នប្រយែងនោះ គឺនិងមានមនុស្សសម្តីដែមបំផ្លាញបោកច្រាស់តាមគ្រប់រូបភាព ដូច្នេះទាំងបុរសស្ត្រី គឺមិនត្រូវធាប់ត្រចៀកទន់ជឿទុកចិត្តគេពេកទេ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះប្រកបតែសេចក្តីសុខនឹងគ្នា ។

ឆ្នាំម្សាញ់ : (ពស្យមនុស្សឃ្លួស ធាតុឆ្នើង)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ បើមានរឿងឈ្លោះវិវាទកើតញើវ ចូរចេះអត់ធ្មត់ និងរម្ងាប់ចិត្តឲ្យបានត្រជាក់ ។ ចំពោះស្ត្រីកេទក្នុងរយៈពេលនេះមិនត្រូវនិយាយស្តីប៉ប៉ាច់ប៉ប៉ាច់ចេចគេបានការច្រើនពេកទេ ព្រោះរឿងរ៉ាវផ្សេង។អាចកើតពីពាក្យសម្តី ។ ចំពោះគូស្វាមីភរិយា ចូរប្រយ័ត្នប្រយែងក្រែងមានអ្នកទីបីចូលជ្រៀតជ្រែក ។

ឆ្នាំមមី : (ពស្យធេព្ពាស្ត្រី ធាតុឆ្នើង)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹម។ ។ ក្នុងរយៈពេលនេះដោយទំនាយទាយថា អាចបង់ខាតទ្រព្យខ្លះ។នោះ ដូច្នេះចូរកុំឲ្យគេខ្ចីរបស់របរមានតម្លៃឲ្យសោះ ព្រោះកាលបើបានធ្លាក់ដល់ដៃគេហើយ គឺគ្មានថ្ងៃបានវិលត្រឡប់វិញឡើយ ។ ចំពោះគូស្វាមីភរិយាក្នុងរយៈ ពេលនេះមានផលប៉ះទង្គិចគ្នាបន្តិចបន្តួច ។

ឆ្នាំមមែ : (ពស្យធេព្ពាស្ត្រី ធាតុមាស)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែមានភោគផលចំណូលហូរចូលច្រើនគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេកហើយក៏មិនខុសពីទូកធំក្តោងធំនោះដែរ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះទាល់តែចេះអត់ឱនឲ្យគ្នាទៅវិញទៅមកទើបមិនអាចប្រេះឆាគ្នាបាន ។

ឆ្នាំវក : (ពស្យយក្សឃ្លួស ធាតុជើក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ចូរកុំធ្វេសប្រហែសឲ្យសោះ ជាពិសេសចំពោះអាជីវកររកស៊ីលក់ដូរមុនឌឺងប្រគល់ ឬទទួលនូវមុខទំនិញសព្វសារពើ ចូរចេះពិនិត្យមើលគុណភាពនិងរាប់ចំនួនឲ្យបានត្រឹមត្រូវ ។ ចំពោះគូស្វាមីភរិយា ចូរប្រយ័ត្នអ្នកក្រៅមកញុះញង់ ។

ឆ្នាំរកា : (ពស្យយក្សឃ្លួស ធាតុជើក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះអ្វី ។ច្រើនមានការប្រែប្រួលពុំទៀងទាត់ញើយ ។ ដូច្នេះបើលោកអ្នកមានទិញលក់ដីធ្លីផ្ទះ ឬវត្ថុមានតម្លៃផ្សេង។ ចូរធ្វើលិខិតស្នាមដោយមានចុះហត្ថលេខា ឬផ្តិតស្នាមមេដៃឲ្យបានត្រឹមត្រូវទើបទៅថ្ងៃមុខពុំមានបញ្ហាចោទញើវ ។ ចំពោះគូស្នេហ៍ប្រកបតែសេចក្តីសុខក្សេមក្សាន្ត ។

ឆ្នាំច : (ពស្យយក្សស្ត្រី ធាតុដី)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបឧទិដ្ឋរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ចូររៀបចំគម្រោងផែនការជាមុនទើបពុំមានការខ្ជោះធ្លោយ ។ ក្រៅពីនោះបើមានរឿងឈ្លោះវិវាទកើតញើវ ចូរចេះអត់ធ្មត់ និងរម្ងាប់ចិត្តឲ្យបានត្រជាក់ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ។ គូស្នេហ៍ក្នុងរយៈពេលនេះ ច្រើនពាក់មុខឲយក្យដាក់គ្នា ។

ឆ្នាំកុរ : (ពស្យមនុស្សស្ត្រី ធាតុទឹក)

រាសីលោកអ្នកញើវខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែការងាររកស៊ីរបស់លោកអ្នកបានជួបឧទិដ្ឋគូប្រជែងជើងខ្លាំងយ៉ាងណាក្តីក៏មិនតឹយព្រួយអ្វីដែរ ព្រោះលោកអ្នកមានប្រៀបឈ្នះដាច់ជានិច្ច ។ ចំពោះកំលោះក្រមុំក្នុងរយៈពេលនេះអាចទាក់ទងគ្នានឹងបានក្លាយជាគូស្នេហ៍ដ៏ប្រពៃមួយគូ ។

សោភ័ណភាព

រូបមន្តធ្វើឱ្យស្បែកមុខសថ្លា

រូបមន្តទាំងពីរខាងក្រោមនេះ វាអាចជួយឲ្យស្បែកមុខរបស់អ្នកថាប់សស្រស់ថ្លាតាមបែបធម្មជាតិល្បើនបំផុត ។

រូបមន្តទី១ : ដើម្បីឲ្យស្បែកមុខញើវសថ្លា មានចំណែកជ្រុំដូចតទៅ គឺទឹកអំពិលទុំ ទឹកដោះគោជូរ ទឹកឃ្មុំ ។

វិធីធ្វើ : យកវត្ថុធាតុដើមទាំងពាលាយបញ្ចូលគ្នា រួចប្រើបែងចែកទឹកល្បាយនេះពាក់កណ្តាលទៅកំដៅទៅលើភ្លើងកិច ។ក្រុចូលគ្នាឲ្យសព្វ ។ បន្ទាប់មកលើកទុកឲ្យត្រជាក់ទើប ច្រកចូលនូបករណ៍អ្វីមួយរក្សាទុកក្នុងទូទឹកកកអាចប្រើបានយូរថ្លៃ ។

វិធីប្រើ : លុបលាងមុខឲ្យស្អាត រួចយកទឹកល្បាយដែលជ្រុំរួចមកលាបឲ្យសព្វលើថ្ពែមុខ និងបំពង់ក លើកលែងរង្វង់ភ្នែកទុកចោលប្រមាណពី២០-៣០នាទី ទើបលាងចេញ ។ ប្រសិនបើបង់ចាប់ឃើញលទ្ធផល គួរលាបវានៅពេលត្រជាក់យកចេញពីទូទឹកកកភ្លាម ។ ។

រូបមន្តទី២ : មុខស្រស់ថ្លាបែបធម្មជាតិ មានចំណែកជ្រុំ គឺម្យ៉ាត្រាប់ ម្យ៉ាល្បៀត ទឹកអំពិល ឬក្រូចឆ្មារ ។

វិធីធ្វើ : យកម្យ៉ាត្រាប់ទៅរំលាយឲ្យមានសភាពខាប់ ។ រួចលាយជាមួយម្យ៉ាល្បៀត បន្ទាប់មកចាក់ទឹកអំពិល ឬក្រូចឆ្មារកូរអោតដល់ក្លាយជាសាប់មួយ ។

វិធីប្រើ : លាងផ្ទៃមុខឲ្យស្អាត បន្ទាប់មកយកល្បាយដែលធ្វើបានមកលាបនៅលើស្បែកទុកចោលរហូតស្ងួត ទើបចាប់ផ្តើមប្រើទឹកស្អាតលាងដម្រះតាមក្រោយទុកជាការស្រេច ។

ពេលនេះអ្នកជឺងហើយថា រូបមន្តធាប់ធ្វើឲ្យស្បែកមុខ សតាមបែបធម្មជាតិ មានវិធីងាយស្រួលបំផុត ទោះបីយ៉ាងណា សូមកុំភ្លេចយកទៅសាកល្បងគ្រប់ ។គ្នាកុំខាន ។

វិធីជួយឱ្យរង្វង់ភ្នែកមានភាពទាក់ទាញ

ក្នុងរឿងសោភ័ណភាពស្រស់ស្អាតរបស់ស្ត្រី ពិតជាមានរឿងតែរង្វង់ភ្នែកចូលរួមជង់ដែរ ព្រោះការមានរង្វង់ភ្នែកស្រស់ស្អាតក៏ជាការទាក់ទាញបំណាប់អារម្មណ៍ពីអ្នកបានប្រទះឃើញ ជាពិសេសចំពោះភេទផ្ទុយគ្នា ។ ប្រសិនបើអ្នកមានបំណងតែបបនេះ ការពិតវាជាការងាយស្រួលហួសពីការគិតទុកទៅទៀត ដោយមើកអាប់តែបស្ទីលស្រស់សង្ហាតាមវិធីលេង៉ពណីរបស់ខ្ញុំជង់សំអាងដូចជាពណីស្ករមាស ក្រោយពេលបំះជាមួយនឹងគ្រឿងភ្លើង ។ វិធីនេះ សំក្តីសមទាំងការចូលរួមកម្មវិធីពេលថ្ងៃ និងពេលយប់ផ្ទាំងជង់ ។

ប្រសិនបើអ្នកចង់ដឹងពីវិធីតុបតែង់តែរភ្នែកឲ្យស្រស់ស្អាត សូមសាកល្បង់តាមការណែនាំដូចខាង់ក្រោមនេះ ÷

•វិធីទី១ : ជំហានទី១ : ប្រើអាយឆេដូ ពណិ.ស ឬក្រែមលាបស្រាល ។នៅលើត្របកភ្នែក បន្ទាប់មកប្រើម្យ៉ា ពណិ.ស្ករ ពណិមាស ឬម្យ៉ាពណិស្ករ មានពន្លឺមាស ដែលកំពុង់ពេញនិយមបំផុតក្នុង់បច្ចុប្បន្ននេះ ។ បន្ទាប់មកចាប់ផ្តើមគូសអាយលិនណ៊ែរ និង់ប្រើម៉ាស្ការ៉ាពណិខ្មៅ ។

ជំហានទី២ : ចំណែកផ្នែកខាង់អន អាចជ្រើសរើសពណិដូចគ្នាក៏បានដែរ ឬពណិមានប្រហាក់ប្រហែលគ្នាដូចជាពណិទឹកក្រូចលាយមាសក៏ស្អាតបានមួយបែបដែរ ។ បន្ទាប់មកចាប់ផ្តើមលាបលើបស្ទីក (ក្រែមលាបបប្លុមាក់) ពណិស្ករ។

ជំហានទី៣ : បន្ទាប់មកផ្ទៃឆេត ខិង ដោយប្រើប្រ៊ែនសឺ ដេញចាប់ពីបរិវេណចង្កា និង់ថ្ពាស ដើម្បីឲ្យផ្ទៃមុខ ទាំងមូលលេចធ្លោ ។ រួចហើយបន្តដេញពីបរិវេណតែមថ្ពាល់បន្តិចបន្តួច ដើម្បីឲ្យសាច់ថ្ពាល់លិចត្រង់តែញើង និង់ចិទបុង់ក្រោយគេគឺក្តោង់ច្រមុះ ។

ត្រាន់តែអនុវត្តតាមការណែនាំមកខាង់លើនេះ ផ្ទៃមុខរបស់អ្នកទាំងមូលជាពិសេសរង្វង់ភ្នែកពិតជាគ្មានកន្លែង់ណាមួយធ្វើឲ្យ ទើសភ្នែកនោះឡើយ ។

•វិធីទី២ : ជំហានទី១ : ប្រើខ្ទះស៊ីលីវ៉ា ដើម្បីលុបបំបាត់ស្នាមដំនៅក្រោមរង្វង់ភ្នែកបន្ទាប់មក ទើបប្រើម្យ៉ាច្រូនាប់ និង់ម្យ៉ាម៉ដ្ឋឲ្យពេញផ្ទៃមុខ ។ ដំណាក់កាលបន្តប្រើក្រែមថ្ពាសពណិបែកង់នៅលើតែមថ្ពាល់ទាំងសង់ខាង់រួចហើយប្រើម្រាមដៃឈ្វីឲ្យបែកជុំវិញរង្វង់ថ្ពាល់ ។ បន្ទាប់មកចាប់ប្រើក្រែមថ្ពាស់ពណិស៊ីដម្លូត្រង់បរិវេណដើមភ្នែកខាង់មុខនៃថ្ពាល់ ដោយកុំភ្លេចវាសទៅជុំវិញឲ្យចូលសាច់ល្អ ។

ជំហានទី២ : ចាប់ផ្តើមប្រើអាយ ឆេដូពណិស៊ីដម្លូខ្ចី ទៅជុំវិញបរិវេណកន្ទុយភ្នែក រួចហើយកៀសឲ្យពេញត្របកភ្នែកផ្នែកខាង់លើ ។

ជំហានទី៣ : ចាប់ប្រើអាយ ឆេដូពណិខ្មៅ លាយស្វាយឲ្យពេញត្របកភ្នែកផ្នែកខាង់ក្រោមរួចកៀសដេញញើង់ទៅលើដូចជាអាយឆេដូពណិស៊ីដម្លូដែរ។

ជំហានទី៤ : គូសជាយត្របកភ្នែកទាំង់លើ និង់ខាង់ក្រោមដោយប្រើ



ហ្គូអ៊ីតលីណ៊ែរ ពណិខ្មៅលាយប្រផេះ ។ ចាប់ផ្តើមគូសជាយត្របក ភ្នែកផ្នែកខាង់លើចាប់តាំង់ពីក្បាលភ្នែករហូតដល់កន្ទុយភ្នែក ។ ចំណែកខាង់ក្រោមវិញចាប់តាំង់ពីកន្ទុយភ្នែករហូតទៅដល់ពាក់កណ្តាលភ្នែក ។ បន្ទាប់មកលាបពីរលើដោយប្រើអាយឆេដូពណិបែកង់ចាស់ រួចហើយប្រើអាយឆេដូពណិមាស ពន្លឺគជ់ខ្ចង់ត្រង់បរិវេណដើមភ្នែកដើម្បីជួយបង្កើនភាពស្រស់ថ្លា ។ ចុង់ក្រោយ គឺពាក់រោមភ្នែកឲ្យង់ញើង់ដោយប្រើម៉ាស្ការ៉ា លាបពីរលើ ។

ជំហានទី៥ : បិទចុង់ក្រោយគេបង្អស់ដោយការលាបបបូរមាក់ឲ្យស្អាតដោយប្រើក្រែម ។ ប្រសិនបើអ្នកញ៉ាយាមតាមការពោលណែនាំទាំង់២វិធីខាង់លើនេះ ដោយប្រឹកប្រឿង និង់យកចិត្តទុកដាក់នោះយើង់ជឿជាក់ថា តែរភ្នែករបស់អ្នកនឹង់ពោរពេញទៅដោយសោភ័ណភាពគួរឲ្យទាក់ទាញបំផុតសម្រាប់អ្នកដែលបានជួបប្រទះ ។

លិខិតផ្ញើជូនកាយកខ្មែរប៉ុស្តិ៍

ពីនាយកសមាគមPassyunk Square Civic Association

•••នាយកសមាគមនៅហ្វីឡាខាងត្បូងមួយនេះ គឺ ក្រីស្ទីន ណាប់ បានសម្តែងមនោសញ្ចេតនាចង់ឃើញសហគមន៍ទាំងអស់ដែលរស់នៅម្តុំផ្លូវលេខ ៦ ដល់ Broad Street នាំគ្នាប្រមូលកម្លាំងដើម្បីកែលំអរតំបន់ដែលអ្នកទាំងអស់គ្នារស់នៅ ។ សហគមន៍ខ្មែរ-ឡាវ ដ៏មានចំនួនច្រើននៅទីនោះ ក៏មានសេចក្តីត្រូវការចង់ឱ្យតំបន់របស់ខ្លួនមានការផ្លាស់ប្តូរប្រសើរឡើងដែរ ។

មិត្តអ្នកអានពិតជាឆ្ងើយតបយ៉ាងវិជ្ជមានជាមិនខាន ។

After recently traveting through Victnam, Laos and Cambodia, I have returned to my South Philadelphia black feeling like I understand more about my neighbors, many of whom have come from these and other countries. And I am more convinced than ever that all member of our community - no matter their age, race, ethnicity or income- must come together if we are to keep improving our city and our neighborhoods to make them safer, cleaner healtheir places to live, play and work.

That is why I invite Cambodian-Americans, and all other members of the Passyunk Square neighborhood to join the efforts of the Passyunk Aquare Civic Association (PSCA). The mission of PSCA is to enhance the quality of live in the neighborhood, preserve the neighborhood´s unique historic character and to promote a cohesive community of residents, businesses and institution. Our efforts include reviewing zoning applications, getting trees planted, paying for a professional street-cleaning program, improving a local schppl, and holding events that allow neighbors to get to know each other. Our meetings are held on the 1th Tuesday of each month at 6:30 at the South Philadelphia Older Adult Center at Dickinson St. and Passyink Ave. You can also learn more at.

Even if you don´t live in Passyunk Square, all residents should seek out their local civic or neighborhood association to learn about their program and to find out how you can get involved. There is no better way to become better connected to you community, and to make a positive impact on your neighborhood. With all of our neighbors united, we can manke strong communities for our families and our future.

Christine Knapp, Presdent of the Passyunk Square Civic Association

ស្ត្រីខ្មែរដំបូងបង្អស់ដែលបានធ្វើដំណើរពីប្រទេសចាកឆ្ងាយមកភ្នំពេញតាមផ្លូវគោក

(តពីលេខមុន)

ដោយ : ពិន នារីពិទូ

•••ពួកយើងបានមកដល់ ABarnaul ដែលមានចំងាយជាង៦០០គីឡូម៉ែត្រពី OMSK ដែលជាទីក្រុងសំបូរទៅដោយធនធានរ៉ែក្រោមដីច្រើនជាងគេ ដូចជា រ៉ែស្ពាន់ និងប្រាក់។ អាកាសធាតុនារដូវនេះ គឺ ១៣ អង្សាសេ ក្រោមពន្លឺព្រះអាទិត្យព្រិចៗដែលបង្កភាពងាយស្រួលក្នុងការធ្វើដំណើរ ចំណែកឯរថយន្តម៉ាកតូយូតា ដែលបានបើកបរមកដល់ពេលនេះមិនមានការខូចខាតអ្វីជាសំខាន់នៅឡើយ ប៉ុន្តែចាំបាច់ត្រូវការទូរសេវ៉ាថែទាំម៉ាស៊ីន និងចាក់បំពេញប្រេងតែប៉ុណ្ណោះ ។ ពួកយើងបានមកដល់ទីនេះនាពេលរសៀលដោយខកខានមិនបានជួបជាមួយភ្នាក់ងារ Sputnik-Altai ដោយទីនេះត្រូវបានបិទទ្វារ ពួកយើងក៏បានផ្ញើសារតាមរយៈ e-mail ជាបន្តទៀត ដើម្បីស្វែងរកភ្នាក់ងារទេសចរណ៍ ដែលទាក់ទងនឹងសេវាចុះបញ្ជី VISA របស់ពួកយើង។ ទោះបីជាមិនមានគំរោងក្នុងការដើរកំសាន្តនាទីនេះក៏ដោយ នារសៀលពួកយើងនៅតែអាចឆ្លៀតឱកាសដើម្បីដើរទស្សនាទីក្រុងនេះ ដែលបរិយាកាសពោរពេញទៅដោយក្តីរីករាយក្នុងល្បែកំប៉ាត់នានិទាឃរដូវ ព្រមទាំងការស្នាក់នៅលើដីកក់ក្តៅតាមបែបគុរាណនាជាយក្រុង Gorno Altaisk ដែលនៅជាប់នឹងទន្លេ Katun និងស្ពាន Aia ក្រោមពន្លឺចែងចាំងពណ៌មាសនៃព្រះអាទិត្យធ្វើឱ្យអារម្មណ៍ស្រស់ថ្លា។ សូមអរគុណដល់ស្ថានទូតបារាំងប្រចាំនៅប្រទេសរុស្សីនេះផងដែរ ដែលបានជួយសំរបសំរួលដល់បញ្ហានានា។ ពួកយើងបានផ្ញើឯកសារតាមរយៈទូរលេខទៅកាន់ភ្នាក់ងារប្រចាំនៅតំបន់ Gorno កន្លងមកពួកយើងបានស្វែងរកទីតាំងនានាព្រមទាំងប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរ និងភ្នាក់ងារទេសចរណ៍តាមរយៈប្រពន្ធ័អ៊ិនធើណេតការផ្ញើសារតាមអ៊ីម៉ែល។

ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៦ : ពួកយើងបានទទួលលិខិតអនុញ្ញាតិពីអាជ្ញាធរឱ្យចុះបញ្ជី VISA នៅក្នុងតំបន់ Altai តាមរយៈអ៊ីម៉ែល នាព្រឹកនេះ។

អ្នកលី Aurélie និងស៊ីលវីយ៉ា Sylvia

ដោយសារតែមិនអាចអានភាសារុស្សីបាន បុគ្គលិកទីនោះក៏បានជួយបំពេញនូវទំរង់បែបបទនៃលិខិត VISA ចប់សព្វគ្រប់ ។ បន្ទាប់ពីមានលិខិតស្របច្បាប់រួចមក ពួកយើងក៏បន្តដំណើរទៅ Lake Teleskoe ជួបជាមួយនឹងចេនី Jeny ជាជនជាតិរុស្សី ដែលអាចទំនាក់ទំនងជាភាសាអង់គ្លេសបាន រួមទាំងមិត្តភ័ក្ត្រជនជាតិបារាំងម្នាក់របស់នាង ដែលបានធ្វើដំណើរផ្សងព្រេងផ្ទុយទិសពីប្រទេសវៀតណាម ត្រឡប់ទៅប្រទេសបារាំងវិញ។

ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៦ : ស្ថិតនៅ Artybach នាពេលយប់ម៉ោង១១ មានរបស់របរខ្លះដែលនៅក្នុងឡានមួយចំនួនត្រូវបានបាត់បង់ដូចជាវិទ្យុ និងឧបករណ៍ឡាន កាមេរ៉ា ផូរស័ព្ទដៃ នាឡិកាដៃ និងវ៉ែនតាមួយគូរ ដែលសុទ្ធសឹងតែជារបស់ថ្មី ពួកយើងក៏បានផ្តល់ដំណឹងដល់ខាងរដ្ឋបាលជំរុំនៅក្នុងតំបន់ Alta នេះផងដែរ។ ក្រោយមករថយន្តតូយូតា ត្រូវបាននាំទៅ garage ដើម្បីបំពាក់គ្រឿងការពារសុវត្ថិភាព ហើយពួកយើងក៏បានឆ្លៀតឱកាសដើម្បីដើរទស្សនាជុំវិញទីក្រុង Gorno Altaisk នេះ។

ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ : ពួកយើងបានចាកចេញពីតំបន់ខ្ពង់រាប Kur Kechua ដើម្បីឈានដល់ព្រំប្រទល់នៃប្រទេសរុស្សី និងមុងហ្គោលី ការបើកបរនៅតាមផ្លូវដែលប្រកបដោយទេសភាពល្អអស្ចារ្យនៃជួរភ្នំ Alta ដែលមានព្រិលគ្របដណ្តប់ពាសពេញ។ ពួកយើងបានឈប់អស់រយៈពេលបីម៉ោងដើម្បីបោះត្រាលើ passport និងបានឆ្លងកាត់ភ្នាក់ងារអន្តោប្រវេសន៍ ដែលនៅតាមព្រំប្រទល់នៃប្រទេសរុស្សីដោយគ្មានបញ្ហា និងបន្តចូលដល់ប្រទេសម៉ុងហ្គោលី តាមព្រំដែនដោយសុវត្ថិភាព ។

(មានតទៅលេខក្រោយ)

Think of life insurance from New York Life as a gift of financial protection. With cash value that increases every year,* even in times like these, your whole life policy can help fund a college education, pay off debts, or let you plan for the unexpected.† And what's more, it's backed by the highest possible ratings for financial strength.‡ Give your family the most selfless gift of all, a secure financial future.

NEW YORK LIFE

Concerned about your family's future? Talk to your New York Life agent today.

Pom Srey
Agent

New York Life Insurance Company
100 Witmer Road Suite 100
Horsham, PA 19044
(215) 441-6280
psrey@ft.newyorklife.com

THE COMPANY YOU KEEP®
www.newyorklife.com

*As premiums are paid. †The cash value in a life insurance policy is accessed through policy loans, which accrue interest at the current rate, and cash withdrawals. Loans and withdrawals will decrease the death benefit and cash value. ‡Standard & Poor's (AAA), A. M. Best (A++), Moody's (Aaa) and Fitch (AAA) for financial strength. Source: Individual Third Party Ratings Reports (as of 6/16/09). © 2009 New York Life Insurance Company, 51 Madison Avenue, New York, NY 10010

100121 AGY-1250 00398624 CV 6/11

Sav-Mor PHARMACY Tel: 215-467-1220

ឱសថស្ថានខ្មែរ

Sav-Mor PHARMAC

Sam EA R.Ph.

2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447

បំរើលោកអ្នកដោយមិត្តភាព និងទាន់ចិត្ត

- Sav Mor គឺជាឱសថស្ថានបំរើការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំតាមវេជ្ជបញ្ជាជាភាសាខ្មែរបាន យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត់សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ និងអន្តរជាតិ

*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.

FOR SALE BY OWNER

HASS´S AUTO ជួសជុលតួឡានដែលបុកគ្នាម្ចាស់ហាងចូលនិវត្តន៍-ហាងមានដំណើរការ១៧ឆ្នាំមកហើយ-ពាណិជ្ជកម្មមានលំនឹងល្អគ្រប់រដូវលោកអ្នកអាចទិញតែពាណិជ្ជកម្មក៏បាន-ទិញដីជាមួយនឹងផ្ទះក៏បាន-ទិញទាំងពីរមួយគ្នាក៏បាន បើចង់ដឹងច្បាស់សូមទូរស័ព្ទរកឈ្មោះ "នីក"

Owner is retiring. 17 years in business at this location. Well established business, all seasons are busy. Option to buy only business, real estate, or both.

Contact Nick: 267-242-7938
615 W. Fisher Ave. Phila, Pa 191203

Coffee Danny's Café

Foods & Hoagies ចានសម្លហូបខ្មែរ និងឡេត

1. Beef Stew Serve with Bread.....នំប៉័ងខគោ
2. Curry Chicken Serve with Bread.....នំប៉័ងការីសាច់មាន់
3. Curry Beef Saramann Serve with Bread....នំប៉័ងសាច់គោ ខការីសារ៉ាម៉ាន់
4. Meatball Soup Serve with Bread .....ស៊ុបប្រហិតជាមួយនំប៉័ង
5. Mi Siam .....មីសៀម

1730 Snyder Ave, Philadelphia, PA 19145 / Mon – Fri: 7am – 7pm Saturday: 9 am – 8 pm / Sunday : CLOSED
Tel: 215.467.4082 Fax: 215.467.4642 / Thank You, Please come again !

FRANK'S TIRES

2654 S. FAIRHILL ST.
(215) 334-2261
OPE N 7 DAYS A WEEK
8 A.M. – 7 P.M.

NEW & USED TIRES
ESTBLISHED SINCE 1984

Totally Traditional!
Totally Cambodielicious!

KAVEI CAMBODIAN RESTAURANT
Authentic Khmer • Thai • Lao • Vietnamese Phở

320 W OREGON AVENUE
(OREGON MARKET, SOUTH PHILLY)

215.952.6688

OPEN 7 DAYS A WEEK
9am-10pm